# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Sep-2011, 14:34
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១១

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**
ចំណាត់ថ្នាក់ប្រភេទឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

## ការជំទាស់របស់លោក អៀង សារី នៅនឹងភាពអាច ទទួលយកបាននូវប្រភេទឯកសារដាក់លក់មួយចំនួន

---

**ដាក់ដោយ:**

**សហមេធាវី:**
អាង ឧត្តម
Michael G. KARNAVAS

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន**
ចៅក្រម **ឱ្យ មណី**
ចៅក្រម **យ៉ា សុខន**
ចៅក្រម Silvia CARTWRIGHT
ចៅក្រម Jean-Marc LAVERGNE
ចៅក្រមបម្រុង **យូរ ឱត្តរា**
ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

អនុលោមតាមវិធាន ៨៤(១) និង វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន") លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ ("សហមេធាវីការពារក្ដី") សូមជំទាស់ទៅនឹងភាពទទួលយកបាននូវប្រភេទឯកសារជាក់លាក់មួយចំនួន។ មេធាវីការពារក្ដីសូមស្នើថា ឯកសារមួយចំនួនដែលស្ថិតនៅក្នុងប្រភេទខាងក្រោមនេះពុំបំពេញលក្ខខណ្ឌអប្បបរមានៃយថាភាព ភាពដែលអាចជឿជាក់បាន និងភាពពាក់ព័ន្ធបានទេ ដូចជា៖ **ក.**ឯកសារដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ("DC-Cam") **ខ.**ឯកសារដែលបានមកពីកម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជា ("CGP") **គ.**ឯកសារដែល ក.ស.ព ទទួលបាន **ឃ.**សម្ភារៈដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម **ង.**របាយការណ៍ អត្ថបទស្រាវជ្រាវ និងឯកសារដែលបានបន្សល់ទុកពីសម័យនោះ **ច.**ចម្លើយសាក្សី និង **ឆ.**ប្រតិចារឹកនៅក្នុងសំណុំរឿង ០០១។ សំណើនេះត្រូវបានធ្វើឡើងជាការចាំបាច់ ដោយសារមានឯកសារប្រភេទជាក់លាក់ដែលបានដាក់ដោយភាគីមិនអាចទទួលយកបានទេ ដោយអនុលោមតាម ៨៤(១) និង វិធាន ៨៧(៣)។ ថ្វីត្បិតតែថា អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវដោះស្រាយបញ្ហាជំទាស់ទៅនឹងឯកសារជាក់លាក់នានា តាមករណីជាក់ស្ដែងក៏ដោយ[1] តែការដាក់ការជំទាស់នៅពេលនេះមានគោលបំណងជួយអង្គជំនុំជម្រះសាលាដំបូង ក្នុងការស្វែងរកវិធីសាស្ត្រទូទៅ ដើម្បីទទួលយកឯកសារភស្ដុតាងក្នុងសំណុំរឿង ០០២ នេះ។ ដោយសារការជំទាស់ទាំងនេះមានលក្ខណៈទូទៅនោះ មេធាវីការពារក្ដីសូមរក្សាសិទ្ធិក្នុងការដាក់ការជំទាស់ទៅនឹងឯកសារជាក់លាក់នានាតាមករណីជាក់ស្ដែង ទៅតាមការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង[2]។

## I. ច្បាប់ជាធរមាន

### ក. បទដ្ឋានក្នុងការទទួលយកភស្ដុតាងជាឯកសារដែលមានចែងក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក

១. មាត្រា ៣៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក បានតម្រូវថា អង្គជំនុំជម្រះសាលាដំបូងត្រូវធានាថាកិច្ចដំណើរការនីតិវិធី "ត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័ស [និង] ... សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[1] *សូមមើល* ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើលេខ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 បន្ទាប់ពីការប្រជុំរៀបចំសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១, ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១, ឯកសារលេខ E74 ទំព័រ ៣។

[2] *ដូចជើងទំព័រខាងលើ*។

[("ICCPR")]"[3]។ ក្នុងចំណោមសិទ្ធិនានាដែលត្រូវបានធានាដោយមាត្រា ១៤ និង ១៥ នៃ ICCPR លោក អៀង សារី មានសិទ្ធិត្រូវបានគេសន្មតថាគ្មានទោស សិទ្ធិការពារខ្លួនប្រឆាំងនឹងការចោទប្រកាន់ចំពោះខ្លួនឯង និងសិទ្ធិក្នុងការសាកសួរដេញដោល។ មាត្រា ៣៣ ថ្មីចែងពីលក្ខខណ្ឌតម្រូវចំនួនពីរគឺ "*ភាពយុត្តិធម៌*" និង "*ភាពឆាប់រហ័ស*"។

## ខ. បទដ្ឋានដែលអនុវត្តចំពោះការទទួលយកភស្តុតាងជាឯកសារដែលមានចែងក្នុងវិធាន

២. វិធាន ៨៤(១) និង វិធាន ៨៧ រួមគ្នា បានចែងពីភាពដែលអាចទទួលយកបានជាភស្តុតាងសក្ខីកម្ម (មានន័យថា ដែលពុំបានកត់ត្រាទុកពីសម័យនោះ)[4]។ ភស្តុតាងជាឯកសារដទៃទៀតដែលអាច

---

[3] *សូមមើលផងដែរ* វិធាន ២១(១)(ក)៖ "ដំណើរការនីតិវិធីនៅ អ.វ.ត.ក ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ ..."។

[4] តុលាការព្រហ្មទណ្ឌអន្តរជាតិក៏បានបែងចែកដាច់ពីគ្នាផងដែរ រវាងលក្ខខណ្ឌតម្រូវនៃភាពដែលអាចទទួលយកបានសម្រាប់ភស្តុតាងសក្ខីកម្ម និងភស្តុតាងជាឯកសារ។ *សូមមើល* Christopher Gosnell, *Admissibility of Evidence* ("Gosnell"), នៅក្នុង KARIM A. A. KHAN, CAROLINE BUISMAN & CHRISTOPHER GOSNELL EDS., PRINCIPLES OF EVIDENCE IN INTERNATIONAL CRIMINAL JUSTICE 403, 404, 406 (Oxford 2010) ("KHAN, BUISMAN & GOSNELL")៖ "នៅតុលាការ ICTR មានពីរប្រភេទគឺ៖ (១).សំណេរដែលពុំបានកត់ត្រាពីសម័យនោះ (ដែលត្រូវចាត់ទុកជាចម្លើយសក្ខីកម្ម គឺជាកម្មវត្ថុដែលមានចែងក្នុងវិធាន ៩២*ស្ទួន* [នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការ ICTR]) និង (២).សំណេរដែលបានកត់ត្រាទុកពីសម័យនោះ (ដែលត្រូវបានចាត់ទុកជាភស្តុតាងជាឯកសារ គឺជាកម្មវត្ថុដែលមានចែងពីបទដ្ឋាននៃតម្លៃជាភស្តុតាងក្នុងវិធាន ៨៩(គ))។ ប្រភេទទាំងពីរនៅតុលាការ ICTY គឺ៖ (១).ចម្លើយដែលបានរៀបចំដោយភាគី (មានចែងក្នុងវិធាន ៩២*ស្ទួន*) និងភស្តុតាងដទៃទៀត (ដែលជាកម្មវត្ថុដែលមានចែងពីបទដ្ឋាននៃតម្លៃជាភស្តុតាងក្នុងវិធាន ៨៩(គ) [នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការ ICTY]...។ រូបភាពដែលបញ្ចូលគ្នាពី [តុលាការ ICTY និង តុលាការ ICTR] ... គឺជាចម្លើយសក្ខីកម្មបានផ្តល់នាសម័យក្រោយ គឺជាកម្មវត្ថុនៃបទដ្ឋានដែលមានចែងក្នុងវិធាន ៩២*ស្ទួន* និងភស្តុតាងជាឯកសារដែលត្រូវបានបង្កើតឡើងក្នុងសម័យកាលនោះ គឺជាកម្មវត្ថុនៃភាពបត់បែនទូលំទូលាយនៃវិធាន ៨៩(គ) ...។ នៅទីបញ្ចប់ តុលាការទាំងពីរបានបែងចែកដាច់ពីគ្នារវាងភស្តុតាងសក្ខីកម្ម និងភស្តុតាងជាឯកសារ ដោយផ្អែកលើពេលវេលានៃការបង្កើត និងភាពបន្ទាន់នៃការសង្កេតទៅលើព្រឹត្តិការណ៍ដែលបានរៀបរាប់មក។ *សូមមើលផងដែរ* Marc Nerenberg & Wibke Timmermann, *Documentary Evidence* ("Nerenberg & Timmermann") *នៅក្នុង* KHAN, BUISMAN & GOSNELL 445-46៖ "ដោយសារគោលការណ៍ខុសគ្នាកំណត់អំពីភាពដែលអាចទទួលយកបានរបស់ភស្តុតាងទាំងនោះ គួរមានការបែងចែកដាច់ពីគ្នារវាងភស្តុតាងជាឯកសារ "សក្ខីកម្ម" ពោលគឺភស្តុតាងសក្ខីកម្មដែលត្រូវបានកត់ត្រាទុក (ភស្តុតាងដែល*ជំនួស*សក្ខីកម្ម ដូចជា ចម្លើយ ប្រតិចារឹកជាដើម) និងភស្តុតាងផ្សេងៗទៀត ដែលជាភស្តុតាងឯកសារ "មិនមែនជាសក្ខីកម្ម" ដែលមានភាពខុសៗគ្នាជាច្រើន ...។ ជាការសំខាន់ផងដែរ ដែលតម្រូវឱ្យមានការបែងចែកដាច់ស្រឡះពីគ្នា រវាងឯកសារដែលត្រូវបានបង្កើតឡើងជាផ្នែកមួយ ឬ ដើម្បីជាការឆ្លើយតបទៅនឹងព្រឹត្តិការណ៍នានាដែលបានបន្សល់ទុកពីសម័យកាលនោះ ត្រូវបានពិនិត្យយ៉ាងហ្មត់ចត់ (ដូចជាកំណត់ហេតុផ្នែកយោធា ឬ អត្ថបទសារព័ត៌មានដែលបានបន្សល់ទុកពីសម័យកាលនោះ) និងឯកសារដែលបានដាក់បញ្ចូលគ្នានាពេលក្រោយមកទៀត ជា

ទទួលយកបានត្រូវតែស្របទៅតាមលក្ខខណ្ឌដែលមានចែងក្នុងវិធាន ៨៧(៣)។ គោលការណ៍ច្បាប់នានាដែលនឹងលើកយកមកពិភាក្សាក្នុងផ្នែកនេះ កំហិតត្រឹមតែជាការពិចារណាចំពោះលក្ខខណ្ឌនៃភាពដែលអាចទទួលយកបាន ទាក់ទិននឹងភស្តុតាងជាឯកសារតែប៉ុណ្ណោះ។ ទាក់ទិននឹងភស្តុតាងជាសក្ខីកម្ម មេធាវីការពារក្តីសូមយោងទៅដល់សារណាផ្នែកច្បាប់មុនៗដែលខ្លួនបានដាក់ ទាក់ទិននឹងការបកស្រាយវិធាន ៨៤(១) ដែលមាននៅក្នុងចម្លើយតបរបស់ លោក អៀង សារី ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឲ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ[5]។

៣. វិធាន ៨៧(១) ចែងថា "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក"។ នេះជាការបញ្ចូលគោលការណ៍នៃប្រព័ន្ធច្បាប់ស៊ីវិលស្តីពី "ការថ្លឹងថ្លែងដោយសេរីអំពីតម្លៃភស្តុតាង" ទៅក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក ដែលថា បើតាមគោលការណ៍នេះ តុលាការជាអ្នកវាយតម្លៃទៅលើភស្តុតាង ដែលទទួលបានក្នុងពេលសវនាការទាំងមូលដោយឥស្សរចិត្ត

---

ពិសេសក្នុងដំណាក់កាលត្រៀមរៀបចំសវនាការ)"។ *សូមមើលផងដែរ* JUDGE RICHARD MAY & MARIEKE WIERDA, INTERNATIONAL CRIMINAL EVIDENCE 209 (Transnational Publishers, 2002) ("MAY & WIERDA") ស្តីពីភស្តុតាងជាឯកសារ៖ "សម្រាប់ជាគោលបំណងនៃការពិភាក្សានេះ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ មានភស្តុតាងជាឯកសារពីរប្រភេទគឺ៖ (១).ចម្លើយជាលាយលក្ខណ៍អក្សរដែលត្រូវបានផ្តល់ដោយយោងទៅលើភស្តុតាងផ្ទាល់មាត់ និង (២).ភស្តុតាងនានាដែលមានកត់ត្រាទុកនូវព័ត៌មាន"។

[5] ចម្លើយតបរបស់ លោក អៀង សារី ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឲ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារលេខ E96/3, ពីកថាខណ្ឌ ១២ ដល់កថាខណ្ឌ ២០។

របស់ខ្លួន[6] ដោយមានការយល់ដឹងថា ក្នុងករណីមានការសង្ស័យ ភស្តុតាងនឹងត្រូវថ្លឹងថ្លែងជាប្រយោជន៍យ៉ាងច្រើនបំផុតដល់ជនជាប់ចោទ[7]។

៤. នៅ អ.វ.ត.ក គោលការណ៍ "ការថ្លឹងថ្លែងដោយសេរីអំពីតម្លៃភស្តុតាង" ស្ថិតក្នុងចំណោមគោលការណ៍នានាដែលមានចែងក្នុងវិធាន ៨៧(៣) ដែលផ្តល់អំណាចឆន្ទានុសិទ្ធិដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការច្រានចោលសំណើណាមួយដែលសុំដាក់ភស្តុតាង ប្រសិនបើអង្គជំនុំជម្រះនេះយល់ឃើញថា៖ **ក.មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា ខ.មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ គ.មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ឃ.ច្បាប់មិនអនុញ្ញាត ឬ ង.មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬ គ្មានប្រយោជន៍។** នៅក្នុងសាលក្រមរបស់ខ្លួនលើសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានថ្លឹងថ្លែងទៅលើគុណសម្បត្តិទាំងនេះ និងបានសម្រេចថា៖

> ដើម្បីអាចយកមកប្រើជាភស្តុតាង <u>សម្ភារៈដែលមាននៅក្នុងសំណុំរឿងត្រូវតែបំពេញលក្ខខណ្ឌច្បាស់លាស់នៃភាពពាក់ព័ន្ធ និងភាពអាចជឿបាននៃភស្តុតាង</u>។ អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធមិនទទួលយកធ្វើជាភស្តុតាង នូវសម្ភារៈ

---

[6] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("CPC") មាត្រា ៣២១៖ "លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចជូនបានដោយសេរី។ តុលាការថ្លឹងថ្លែងដោយឥស្សរចិត្ត អំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន"។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ៤២៧៖ "លើកលែងតែច្បាប់ចែងផ្ទុយពីនេះ បទល្មើសអាចត្រូវបានបង្ហាញតាមវិធីណាមួយនៃភស្តុតាងក៏បាន ហើយចៅក្រមត្រូវសម្រេចដោយឥស្សរចិត្តរបស់ខ្លួន"។

[7] *សូមមើល* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់, ឯកសារលេខ E50/3/1/4, កថាខណ្ឌ ៣១៖ "អង្គជំនុំជម្រះតុលាការកំពូល បញ្ជាក់យ៉ាងមុតមាំថា គោលការណ៍វិមតិសង្ស័យជាប្រយោជន៍ដល់ជនជាប់ចោទ *(in dubio pro reo)* ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលកើតចេញពីគោលការណ៍ការសន្មតទុកជាមុនថាគ្មានទោស និងដែលមានចែងជាមូលដ្ឋានក្នុងប្រព័ន្ធគតិយុត្តរបស់កម្ពុជាផងដែរនោះ មានមុខងារចម្បងក្នុងការបង្ហាញឱ្យឃើញនូវការយល់ដឹងជាស្វ័យប្រវត្តិ ក្នុងករណីដែលពុំមានភស្តុតាងលុបបំបាត់ភាពមន្ទិលសង្ស័យ"។ នៅតុលាការ ICTY គោលការណ៍វិមតិសង្ស័យជាប្រយោជន៍ដល់ជនជាប់ចោទ *(in dubio pro reo)* ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជាលទ្ធផលនៃគោលការណ៍សច្ចាធារណ៍និរទោស និងបន្ទុកភស្តុតាងដែលហួសពីវិមតិសង្ស័យ។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកដទៃទៀត*, សំណុំរឿងលេខ IT-96-21-T, សាលក្រម ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៦០១។ នៅក្នុងសាលក្រមនោះ មានការទទួលស្គាល់ទាក់ទិនទៅនឹងសំអាងហេតុដែលចាំបាច់សម្រាប់ការចោទប្រកាន់ ដូចជាសំអាងហេតុដែលបង្កើតជាធាតុផ្សំនៃបទល្មើសដែលត្រូវបានចោទប្រកាន់។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lima និងអ្នកដទៃទៀត*, សំណុំរឿងលេខ IT-33-66-A, សាលក្រម ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៧, កថាខណ្ឌ ២១។

ណាមួយ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងវិធាន ៨៧(៣) នៃ វិធានផ្ទៃក្នុង (ដូចជាភាពមិនពាក់ព័ន្ធ ភាពមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុ ដែលបានចោទប្រកាន់ ភស្តុតាងដែលមិនអាចរកបានក្នុងរយៈពេលសមស្រប ឬ ដោយសារអត្ថិភាពនៃការរំលោភបំពានលើបទដ្ឋានច្បាប់ជាសារវ័ន្ត ដែលពាក់ព័ន្ធ នឹងវិធាននៃភស្តុតាង)[8]។

៥. ក្នុងឱកាសមួយផ្សេងទៀត អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា អានុភាពនៃវិធាន ៨៧(៣) នោះគឺថា "ដើម្បីអាចយកមកប្រើជាភស្តុតាង សម្ភារៈដែលមាននៅក្នុងសំណុំរឿងត្រូវតែ ... បំពេញឲ្យបាននូវបទដ្ឋានអប្បបរមានៃភាពពាក់ព័ន្ធ និងភាពគួរឲ្យជឿជាក់បាននៃភស្តុតាង ដែលចាំបាច់ដើម្បីឲ្យសម្ភារៈទាំងនោះអាចដាក់ដេញដោលបាន នៅចំពោះមុខអង្គជំនុំជម្រះ។ នៅពេលដែលសម្ភារៈត្រូវបានដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ តម្លៃដាក់បន្ទុកនៃភស្តុតាងនេះ និងការថ្លឹងថ្លែងដើម្បីឲ្យមានការយល់ស្របទៅនឹងភស្តុតាងនោះ នឹងត្រូវបានធ្វើការវាយតម្លៃដោយអង្គជំនុំជម្រះ"[9]។ នៅពេលសម្រេចថាតើគួរទទួលយក ឬមិនទទួលយកសម្ភារៈជាខ្សែភាពយន្តមួយចំនួនក្នុងសំណុំរឿង ០០១ នោះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សម្ភារៈនោះអាចទទួលបាន "ជាកម្មវត្ថុនៃការពិនិត្យឡើងវិញលើភាពពាក់ព័ន្ធ និងយថាភាព[របស់វា]ក្នុងពេលសវនាការលើអង្គសេចក្តី"[10]។ សរុបមក អង្គជំនុំជម្រះសាលាដំបូងបានសម្រេចនៅក្នុងសំណុំរឿង ០០១ ថា ដើម្បីអាចទទួលយកជាភស្តុតាងបាន ឯកសារមួយត្រូវតែបំពេញតាមលក្ខខណ្ឌអប្បបរមាដូចជា៖ **ក.យថាភាព ខ.ភាពដែលអាចជឿជាក់បាន** និង **គ.ភាពពាក់ព័ន្ធ**។

### ១. យថាភាព

---

[8] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧-អវតក/អជសជ, សាលក្រម ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, ឯកសារលេខ E188 ("សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង *ឌុច*"), កថាខណ្ឌ ៤១ (គូសបញ្ជាក់បន្ថែម)។

[9] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧-អវតក/អជសជ, សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩, ឯកសារលេខ E43/4 ("សេចក្តីសម្រេចក្នុងសំណុំរឿង *ឌុច* ស្តីពីភាពអាចទទួលយកសម្ភារៈនៅក្នុងសំណុំរឿង"), កថាខណ្ឌ ៧ (គូសបញ្ជាក់បន្ថែម)។

[10] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧-អវតក/អជសជ, សេចក្តីសម្រេចអំពីភាពអាចទទួលយកបាននៃភស្តុតាងថ្មី និងសេចក្តីណែនាំដល់ភាគីទាំងអស់, ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩, ឯកសារលេខ E/5/10/2 ("សេចក្តីសម្រេចក្នុងសំណុំរឿង *ឌុច* អំពីភាពអាចទទួលយកបាននៃភស្តុតាងថ្មី"), កថាខណ្ឌ ១៦.៤។

៦. យថាភាពនៃឯកសារត្រូវតែបានសម្រេចជាមុន មុននឹងទទួលយកឯកសារនោះមកធ្វើជាភស្តុតាង។ ឯកសារណាមួយដែលមិនមានយថាភាពនឹង "មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង"[11] និងអាចនឹងត្រូវបានសម្រេចមិនទទួលយកដោយអនុលោមតាមវិធាន ៨៧(៣)(គ)។ ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានដកចេញនូវចម្លើយពីរដែលបានចេញដោយ ក.ស.ព និងបានចេញសេចក្តីសម្រេច ដោយផ្អែកលើសំអាងហេតុពីភាពដើមខ្លឹមសារ ចរិតលក្ខណៈមិនឯកភាពគ្នា ព្រមទាំងអលទ្ធភាពរបស់ ឌុច ក្នុងការជជែកតវ៉ាពីការប្រឆាំងជំទាស់របស់ខ្លួន[12]។ នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ("ICTR") "អង្គជំនុំជម្រះអាចស្នើសុំឲ្យមានការផ្ទៀងផ្ទាត់យថាភាពនៃភស្តុតាងដែលទទួលបានក្រៅតុលាការ"[13]។ ទោះបីចំណុចនេះមិនមែនជាវិធានដែលចែងពីភាពដែលអាចទទួលយកបានក៏ដោយ[14] តែមានការរំពឹងទុកថា ភាគីដែលបានដាក់សំណើ (ដែលត្រូវបង្ហាញពីភាពដែលអាចជឿជាក់បាន) ត្រូវបង្ហាញនូវលក្ខណៈមួយចំនួន ដូចជាថាតើឯកសារនេះជាឯកសារប្រភេទអ្វី ហើយថាវាជាឯកសារពិតប្រាកដ ឬមិនពិតប្រាកដ មុនពេលដែលឯកសារនោះត្រូវបានទទួលយកមកធ្វើជាភស្តុតាង[15]។ ហេតុនេះ

---

[11] *ដូចជើងទំព័រខាងលើ*។

[12] សេចក្តីសម្រេចក្នុងសំណុំរឿង *ឌុច* ស្តីពីភាពអាចទទួលយកសម្ភារៈនៅក្នុងសំណុំរឿង, កថាខណ្ឌ ១៦។

[13] វិធាននីតិវិធី និង ភស្តុតាងតុលាការ ICTY និង ICTR, វិធាន ៨៩(ង)។

[14] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកដទៃទៀត*, សំណុំរឿងលេខ IT-96-21-T, សេចក្តីសម្រេចលើសំណើរបស់ចុងចោទ Zejnil Delalić សុំការអនុញ្ញាតដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៨ ចំពោះភាពដែលអាចទទួលយកបាននៃភស្តុតាង, ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៩៨, កថាខណ្ឌ ២០៖ "លក្ខខណ្ឌតម្រូវដោយប្រយោលដែលថា ផ្នែកមួយនៃភស្តុតាងត្រូវបានវាយតម្លៃបឋមថាអាចជឿជាក់បាន ដែលថាវាមានសញ្ញាណនៃភាពជឿជាក់បានពេញលេញនោះ គឺជាកត្តាមួយក្នុងការវិភាគវាយតម្លៃពីភាពពាក់ព័ន្ធ និងតម្លៃជាភស្តុតាងរបស់វា។ ដើម្បីតម្រូវឲ្យមានយថាភាពដាច់ខាតនៃឯកសារ មុនពេលដែលឯកសារនោះអាចត្រូវបានទទួលស្គាល់នោះ គឺជាការតម្រូវដែលមានភាពតឹងរ៉ឹងជាងបទដ្ឋានដែលមានចែងក្នុងអនុវិធាន ៨៩(គ) ទៅទៀត"។

[15] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bagosora*, សំណុំរឿងលេខ ICTR-98-41-T, សេចក្តីសម្រេចពីការទទួលយកឯកសារ Tab 19 of Binder ដែលបានបង្កើតឡើងទាក់ទិននឹងវត្តមានរបស់សាក្សីឈ្មោះ Maxwell Nkole, ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៤, កថាខណ្ឌ ៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកដទៃទៀត,* សំណុំរឿងលេខ IT-05-88-T, សេចក្តីសម្រេចពីភាពអាចទទួលយកបាននៃការទាក់ទងដែលគេស្ទាក់ចាប់បាន, ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០០៧, កថាខណ្ឌ ៣៥៖ "ក្នុងការសម្រេចថាតើឯកសារត្រូវបានវិភាគបឋមថាអាចជឿជាក់បាន ឬមិនអាចជឿជាក់បាននោះ អង្គជំនុំជម្រះសាលាដំបូងត្រូវថ្លឹងថ្លែងថាតើ កម្រិតនៃភាពសមហេតុសមផលនៃអង្គហេតុអាចរកបានពីក្នុងឯកសារនោះ ដូចអ្វីដែលភាគីអ្នកដាក់បានអះអាងថាមាន ដែរឬទេ"

សម្ភារៈដែលមិនមានយថាភាពត្រូវតែមិនមានតម្លៃជាភស្តុតាងនោះទេ។ នៅពេលវិភាគវាយតម្លៃពីយថាភាពនៃភស្តុតាងជាឯកសារ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Musema* នៃតុលាការ ICTR បានថ្លែងថា គេត្រូវថ្លឹងថ្លែងទៅលើទម្រង់ ខ្លឹមសារ និងការប្រើប្រាស់ឯកសារតាមការយល់ឃើញ រួមទាំង៖ **ក.**ថាតើឯកសារនោះជាឯកសារដើម ឬ ជាឯកសារថតចម្លង **ខ.**ប្រសិនបើវាជាឯកសារថតចម្លង ថាតើឯកសារនោះត្រូវបានចុះបញ្ជី ឬ ត្រូវបានដាក់ដោយមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថភាពណាមួយឬទេ **គ.**ថាតើ ឯកសារនោះត្រូវបានចុះហត្ថលេខា ដាក់ក្នុងស្រោមសំបុត្របិទជិត បោះត្រា ឬ មានការបញ្ជាក់តាមវិធីណាមួយផ្សេងទៀតឬទេ និង **ឃ.**ថាតើឯកសារនោះត្រូវបានអនុវត្តសមស្របតាមច្បាប់ឬទេ ដូចជា ត្រូវបានសរសេរ ផលិតឡើង ឬ ទទួលបានការអនុញ្ញាតពីបុគ្គល ឬ ភាគីដែលអះអាងថាជាអ្នកតាក់តែងឯកសារនោះឬទេ[16]។

**២. ភាពអាចជឿជាក់បាន**

៧. ភាពដែលអាចជឿជាក់បាននៃឯកសារត្រូវតែត្រូវបានសម្រេចជាមុន មុននឹងទទួលយកឯកសារនោះមកធ្វើជាភស្តុតាង។ ឯកសារមួយដែលមិនអាចជឿជាក់បាននឹងមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាងនោះទេ ហើយអាចនឹងត្រូវបានសម្រេចមិនទទួលយក ដោយអនុលោមតាមវិធាន ៨៧(៣)(គ)[17]។ ស្ទើរតែគ្រប់ផ្នែកទាំងអស់នៃទម្រង់ ខ្លឹមសារ ឬ ភាពដើមនៃព័ត៌មានអាចជា*ផ្នែកតូចៗ* *(indicium)* នៃភាពដែលអាចជឿជាក់បាន[18]។ មិនមាន "បញ្ជីណាមួយជាក់លាក់បញ្ជាក់ពីលក្ខខណ្ឌតម្រូវដែលអាចមាន" ឬ "មូលហេតុស្វ័យប្រវត្តិសម្រាប់ទទួលយក ឬ ដកចេញពីផ្នែកមួយនៃភស្តុតាង" ទេ[19]។ កត្តានានាដែលត្រូវបានយកមកពិចារណានៅឯតុលាការ*មិនអចិន្ត្រៃយ៍* រួមមាន៖ លក្ខណៈឯកសារ ដែលរួមមាន ហត្ថលេខា ត្រា

---

ប្រសិនបើមិនមានទេ "ពេលនោះ ឯកសារនោះនឹងមិនអាចជឿជាក់បានជាក់ស្តែងទេ ហើយឯកសារនោះមិនមានតម្លៃជាភស្តុតាងដែលកំណត់ដោយវិធាន ៨៩(គ) ឡើយ"។

[16] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Musema,* សំណុំរឿងលេខ ICTR-96-13-T, សាលក្រម និងការផ្តន្ទាទោស, ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០, កថាខណ្ឌ ៦៧-៦៧។

[17] សេចក្តីសម្រេចក្នុងសំណុំរឿង *ឌុច* ស្តីពីភាពអាចទទួលយកសម្ភារៈនៅក្នុងសំណុំរឿង, កថាខណ្ឌ ៧, ១៦។

[18] Gosnell, ត្រង់ទំព័រ ៣៨៦។

[19] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lubanga,* សំណុំរឿងលេខ ICC-01/04-01/06, ទំព័រកំណែពាក្យខុសក្នុងសេចក្តីសម្រេចពីភាពទទួលយកបាននៃឯកសារចំនួនបួន, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ២៩។ សូមមើលខាងលើ កថាខណ្ឌ ២៨, ៣២។

ត្រា ទូរសារ ការដាក់លេខឯកសារ ឬ លក្ខណៈសម្គាល់ដទៃៗទៀត[20]។ មុនពេលចាត់ទុកថា ឯកសារណាមួយមានលក្ខណៈអាចទទួលយកបាន ឯកសារនោះត្រូវមានសញ្ញាណនៃភាពជឿជាក់បានពេញលេញ ដើម្បីជាការវាយតម្លៃបឋមអំពីភាពអាចទទួលយកបាននៃឯកសារនោះ[21]។ ភ្ជាប់ជាមួយនឹងភាពដែលអាចជឿជាក់បាននៃភស្តុតាងនោះគឺតម្លៃជាភស្តុតាង។ បើតាមយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC), ICTY និង ICTR ឯកសារត្រូវបំពេញតាមលក្ខខណ្ឌអប្បបរមាមួយចំនួនស្តីពីភាពអាចជឿជាក់បាន ដើម្បីចាត់ទុកថា ឯកសារនោះមានតម្លៃជាភស្តុតាង[22]។ តម្លៃជាភស្តុតាងនៃឯកសារនោះគឺជា "ខ្លឹមសារខុសៗគ្នាដែលចាំបាច់មានការ

---

[20] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bagosora*, សំណុំរឿងលេខ ICTR-98-41-T, សេចក្តីសម្រេចពីការទទួលយកឯកសារ Tab 19 of Binder ដែលបានបង្កើតឡើងទាក់ទិននឹងវត្តមានរបស់សាក្សីឈ្មោះ Maxwell Nkole, ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២00៤, កថាខណ្ឌ ៨៖ "ការបង្ហាញពីភាពជឿជាក់បានដែលបានធ្វើយុត្តិកម្មចំពោះការទទួលយកឯកសារនៅក្នុងយុត្តាធិការនៃតុលាការ *មិនអចិន្ត្រៃយ៍*រួមមាន៖ ទីកន្លែងដែលទទួលបានឯកសារនោះ ដែលស្របគ្នាទៅនឹងសក្ខីកម្មដែលពិពណ៌នាពីការថែរក្សាឯកសារនោះតាមលំដាប់លំដោយ ចាប់តាំងពីពេលទទួលបានឯកសារ, ភាពស៊ីសង្វាក់គ្នារវាងខ្លឹមសារនៃឯកសារនោះជាមួយនឹងភស្តុតាងផ្សេងទៀត, និងលក្ខណៈខាងក្រៅនៃឯកសារនោះដូចជា ហត្ថលេខា ត្រា ឬ សូម្បីតែទម្រង់ជាការសរសេរដៃឡើងទៅ"។ *រឿងក្តី រដ្ឋអាជ្ញាតទល់នឹង Kordić និង Čerkez,* សំណុំរឿងលេខ IT-95-14/2, សេចក្តីសម្រេចទៅលើពាក្យសុំរបស់រដ្ឋអាជ្ញាទាក់ទិននឹង "វត្តតាង Zagreb" និងប្រតិចារិករបស់ប្រធាន, ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២000, កថាខណ្ឌ ៤៣។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Hadžihasanović និង Kubura,* សំណុំរឿងលេខ IT-01-47-T, សេចក្តីសម្រេចពីភាពអាចទទួលយកបាននៃឯកសារមួយចំនួនដែលត្រូវបានគេជំទាស់ និងឯកសារសម្រាប់បង្ហាញអត្តសញ្ញាណ, ថ្ងៃទី ២ ខែ សីហា ឆ្នាំ ២00៤, កថាខណ្ឌ ២៩៖ "ភស្តុតាងដែលត្រូវបានវិភាគបឋម អាចមានទម្រង់ខុសៗគ្នា ឧទាហរណ៍ដូចជា ប្រភពឯកសារ, ទម្រង់របស់វា (ហត្ថលេខា, ត្រា), រចនាសម្ព័ន្ធរបស់វា (ទូរសារ ឬ លិខិត), វិធីសាស្ត្រនៃការបញ្ជូនឯកសារ, ខ្លឹមសារ ឬ ការប្រើប្រាស់តាមការយល់ឃើញនោះ"។

[21] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកដទៃទៀត,* សំណុំរឿងលេខ IT-96-21-T, សេចក្តីសម្រេចលើសំណើរបស់ចុងចោទ Zejnil Delalić សុំការអនុញ្ញាតដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៨ ចំពោះភាពដែលអាចទទួលយកបាននៃភស្តុតាង, ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៩៨, កថាខណ្ឌ ២0។

[22] បើតាមអង្គជំនុំជម្រះ តុលាការកំពូល ក្នុងរឿងក្តី *Nyiramasuhuko* នៃតុលាការ ICTR, ភាពដែលអាចទទួលយកបានតម្រូវថា "មានការបង្ហាញពីដំបូងថា ភស្តុតាងនោះអាចជឿជាក់បាន" ជាបទដ្ឋានដែលត្រូវគោរពតាម លុះត្រាតែព័ត៌មាននោះ "មិនមានបង្ហាញពីភាពជឿជាក់បាន ទើបមិនមានតម្លៃជាភស្តុតាង"។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Nyiramasuhuko និងអ្នកដទៃទៀត,* សំណុំរឿងលេខ ICTR-98-42-AR73.2, សាលដីកាលើបណ្តឹងរបស់ Pauline *Nyiramasuhuko* ស្តីពីភាពអាចទទួលយកបាននៃភស្តុតាង, ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២00៤, កថាខណ្ឌ ៧។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Hadžihasanović និង Kubura,* សំណុំរឿងលេខ IT-01-47-T, សេចក្តីសម្រេចពីភាពអាចទទួលយកបាននៃឯកសាររបស់មេធាវីការពារក្តី Enver Hadžihasanović, ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២00៥, កថាខណ្ឌ ២១៖ "ឯកសារត្រូវមាន "ភាពពាក់ព័ន្ធខ្លះ" និង "តម្លៃជាភស្តុតាងខ្លះៗ"។ ចំណុចនេះមានន័យថា ដើម្បីឱ្យភស្តុតាងណាមួយអាចទទួលយកបាន អង្គជំនុំជម្រះនេះពុំ

ប្រែប្រួល" តែគេអាចនិយាយបានថា ឯកសារនោះពាក់ព័ន្ធនឹងអង្គហេតុដែលកំពុងពិភាក្សា ពោល គឺ អង្គហេតុដែលបង្ហាញពីពិរុទ្ធភាព និងភាពគ្មានទោស[23]។

### ក. វិធានស្ដីពី "ភស្តុតាងដែលល្អបំផុត"

៨. ជាទូទៅ វិធានស្ដីពី "ភស្តុតាងដែលល្អបំផុត" តម្រូវឲ្យមានភស្តុតាងជាបឋម (ពោលគឺ ភស្តុតាង "ល្អបំផុត") ដើម្បីជាគោលបំណងបង្ហាញពីខ្លឹមសាររបស់ឯកសារណាមួយ[24]។ គោលការណ៍ស្ដីពីការបង្ហាញភស្តុតាងនេះជាគោលការណ៍ណែនាំមួយដែលអនុវត្តនៅតាមតុលាការ *មិនអចិន្ត្រៃយ៍*[25]។

---

ចាំបាច់សម្រេចពីតម្លៃជាភស្តុតាងរបស់វាច្បាស់លាស់ទេ ដោយសារបញ្ហានេះនឹងត្រូវធ្វើការថ្លឹងថ្លែងតែក្នុងដំណាក់កាលក្រោយតែប៉ុណ្ណោះ"។ *សូមមើលផងដែរ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Lubanga, សំណុំរឿងលេខ ICC-01/04-01/06, ទំព័រកំណែពាក្យខុសក្នុងសេចក្ដីសម្រេចពីភាពទទួលយកបានឯកសារចំនួនបួន, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ២៨។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Tadić,* សំណុំរឿងលេខ IT-94-1-T, សេចក្ដីសម្រេចលើសំណើសុំរបស់មេធាវីការពារក្ដីស្ដីពីពាក្យចចាមអារ៉ាម,ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ១៩៩៦, កថាខណ្ឌ ៩៖ "ភស្តុតាង "មានគោលបំណងបង្ហាញពីបញ្ហាមួយ" ត្រូវមានធាតុផ្សំនៃភាពអាចជឿជាក់បានខ្លះដែរ", កថាខណ្ឌ ១៥៖ "ការផ្ដោតលើការសម្រេចថាតើ ភស្តុតាងនោះអាចមានតម្លៃជាភស្តុតាង ឬមិនមាននោះ គឺស្ថិតនៅក្នុងអត្ថន័យនៃបទប្បញ្ញត្តិដែលមានចែងក្នុងអនុវិធាន ៨៩(គ) គួរត្រូវមានកម្រិតអប្បបរមាថា ភស្តុតាងនោះអាចជឿជាក់បាន"។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកដទៃទៀត,* សំណុំរឿងលេខ IT-96-21-T, សេចក្ដីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំទទួលយកភស្តុតាង, ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៨, កថាខណ្ឌ ១៨៖ "ប្រសិនបើភស្តុតាងដែលដាក់មកមិនអាចជឿជាក់បាន ភស្តុតាងនោះមិនអាចពាក់ព័ន្ធ ឬមានតម្លៃជាភស្តុតាងទេ"។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង S. Milošević,* សំណុំរឿងលេខ IT-02-54-T, សេចក្ដីលើការទទួលយកឯកសារដែលទាក់ទិននឹងសក្ខីកម្មរបស់សាក្សីមេធាវីការពារក្ដីឈ្មោះ Dragan Jasović, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥, កថាខណ្ឌ ១៨។

[23] MAY និង WIERDA, ត្រង់ទំព័រ ១០៧។

[24] *សូមមើល* លោកចៅក្រម Peter Murphy និង Lina Baddour, *International Criminal Law and Common Law Rules of Evidence* ("Murphy & Baddour") *នៅក្នុង* KHAN, BUISMAN & GOSNELL, ត្រង់ទំព័រ ១១៥។

[25] *ដូចជើងទំព័រខាងលើ,* ត្រង់ទំព័រ ១១៦, *ដកស្រង់ចេញពី រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Perišić,* សំណុំរឿងលេខ IT-04-81, ដីកាសម្រេចលើគោលការណ៍ណែនាំស្ដីពីការទទួលយក និងបង្ហាញភស្តុតាង និងការប្រព្រឹត្តរបស់មេធាវីនៅក្នុងតុលាការ, ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨, កថាខណ្ឌ ៣៦៖ "មិនមានវិធាននៃតុលាការអន្តរជាតិណាមួយចែងច្បាស់ពីវិធាននៃភស្តុតាងល្អបំផុតទេ។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះសាលាដំបូងជាច្រើននៅតុលាការ ICTY បានអនុម័ត និងបានបញ្ចូលវិធាននេះយ៉ាងច្បាស់ទៅក្នុងគោលការណ៍ណែនាំស្ដីពីការទទួលយកភស្តុតាង នៅក្នុងរឿងក្ដីមួយចំនួន។ ជាទូទៅ គោលការណ៍ណែនាំបែបនោះអះអាងថា៖ "អង្គជំនុំជម្រះសាលាដំបូងនឹងពឹងផ្អែកលើភស្តុតាងល្អបំផុតដែលមាននៅក្នុងស្ថានភាពនៃរឿងក្ដី ...។ ការថ្លឹងថ្លែងថា ភស្តុតាងណាមួយជាភស្តុតាងល្អបំផុតគឺត្រូវពឹងផ្អែកលើស្ថានភាពពិសេសដែលជាប់ជាមួយនឹងឯកសារនីមួយៗ និងភាពស្មុគស្មាញនៃរឿងក្ដីនោះ និងការស៊ើបអង្កេតដែលមានពីមុនៗមកផង"។ *សូមមើល ផងដែរ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Stanišić និង Župljanin,* សំណុំរឿងលេខ IT-08-91-PT, ដីកាសម្រេចលើគោលការណ៍ណែនាំស្ដីពីការទទួលយក និង ការបង្ហាញ

ការសន្មតជាសំខាន់នៃវិធានស្តីពី "ភស្តុតាងដែលល្អបំផុត" គឺថា ភស្តុតាងបន្ទាប់បន្សំដែលបញ្ជាក់ពីខ្លឹមសាររបស់ឯកសារមួយមិនអាចជឿជាក់បានដូចឯកសារផ្ទាល់ឡើយ[26]។ ទោះបីគេចង់បានឯកសារដើមក៏ដោយ ក៏មានករណីខ្លះ ភស្តុតាងបន្ទាប់បន្សំដែលបញ្ជាក់ពីខ្លឹមសាររបស់ឯកសារមួយអាចនឹងត្រូវបានគេទទួលយកផងដែរ[27]។

### ខ. ក្នុងករណីតម្លៃនៃអានុភាពរបស់ភាពលម្អៀងមានទម្ងន់ជាងតម្លៃជាភស្តុតាង

---

ភស្តុតាង IT-95-11-T, ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៩, ឧបសម្ព័ន្ធ ក, កថាខណ្ឌ ១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Martić,* សំណុំរឿងលេខ, សេចក្តីសម្រេចដែលអនុម័តគោលការណ៍ណែនាំស្តីពីបទដ្ឋានដែលគ្រប់គ្រងការទទួលយកភស្តុតាង, ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៦, ឧបសម្ព័ន្ធ ក, កថាខណ្ឌ ៧។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Halilović,* សំណុំរឿងលេខ IT-01-48-T, គោលការណ៍ណែនាំស្តីពីបទដ្ឋានគ្រប់គ្រងការទទួលយកភស្តុតាង, ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៥, ឧបសម្ព័ន្ធ ក, កថាខណ្ឌ ៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić,* សំណុំរឿងលេខ IT-02-60-PT, គោលការណ៍ណែនាំស្តីពីបទដ្ឋានដែលគ្រប់គ្រងការទទួលយកភស្តុតាង, ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៣, ឧបសម្ព័ន្ធ, កថាខណ្ឌ ៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stakić,* សំណុំរឿងលេខ IT-97-24-T, ដីកាសម្រេចបណ្តោះអាសន្នលើបទដ្ឋានដែលគ្រប់គ្រងការទទួលយកភស្តុតាង, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២, ឧបសម្ព័ន្ធ, កថាខណ្ឌ ៧។

[26] *សូមមើល* លោកចៅក្រម Peter Murphy, *No free lunch, no free proof: the indiscriminate admission of evidence is a serious flaw in international criminal trials*, 8(2) J. INT'L CRIM. JUST. 539, 568-69 (2010)៖ "វិធាន [ភស្តុតាងល្អបំផុត] ត្រូវបានបង្កើតឡើងដោយប្រព័ន្ធខំមិនឡូ ដើម្បីព្យាយាមធានាឱ្យបានពីភាពជឿជាក់បាននៃឯកសារមួយជាភស្តុតាង ដែលខ្លឹមសារនៃវិធាននេះគឺជាវិធានភស្តុតាងដ៏ចំណាស់បំផុតមួយ។ វិធាននេះត្រូវបានគេស្គាល់ថាជាវិធានភស្តុតាងបឋម ឬជាវិធានភស្តុតាងដែលល្អបំផុត។ គោលការណ៍របស់វិធាននេះគឺផ្តល់អានុភាពដល់ពាក្យពេចន៍នៅក្នុងឯកសារឱ្យមានភាពសុក្រឹត និងសច្ចភាពតាមដែលអាចធ្វើបាន ...។ វិធាននៅក្នុងប្រព័ន្ធខំមិនឡូគឺថា នៅពេលដែលឯកសារមួយត្រូវបានផ្តល់ជាភស្តុតាងទៅតាមខ្លឹមសាររបស់វា ហើយខ្លឹមសារនោះត្រូវបានជំទាស់នោះ គេត្រូវបង្ហាញឯកសារដើមរបស់វា (ឬ នៅក្នុងករណីដែលមានឯកសារចម្លងច្រើន ឬ ឯកសារដើមច្រើន គេត្រូវបង្ហាញនូវឯកសារមួយក្នុងចំណោមឯកសារទាំងនោះ)។ មានករណីលើកលែងដែរចំពោះវិធាននោះ ... នៅពេលដែលគេមិនអាចបង្ហាញឯកសារដើមបាន ឬ អាចត្រូវបានគេលែងយកមកប្រើប្រាស់ដោយសារមានមូលហេតុផ្សេង។ នៅពេលមានការតម្រូវឱ្យបង្ហាញឯកសារដើម ហើយឯកសារដើមនោះអាចរកបាន គ្មានភស្តុតាងដទៃទៀតណា (ភស្តុតាង "បន្ទាប់បន្សំ") អាចត្រូវបានអនុញ្ញាតឱ្យដាក់នោះទេ។ តែក្នុងករណីលើកលែង នៅពេលដែលភស្តុតាងបន្ទាប់បន្សំត្រូវបានទទួលយកនោះ នៅពេលនោះ ភស្តុតាងបន្ទាប់បន្សំប្រភេទណាក៏អាចដាក់បានដែរ។ ទោះបីវិធាននេះមានលក្ខណៈបច្ចេកទេសក៏ដោយ តែវានៅមានប្រសិទ្ធភាពដដែលក្នុងករណីដែលមានហេតុផលដែលនាំឱ្យមានការសង្ស័យថាឯកសារដើម ឬច្បាប់ដើមដែលថតចម្លង មានចំណុចខ្លះខុសពីឯកសារថតចម្លងដទៃទៀត ឬពីការចងចាំរបស់សាក្សី។ ចំណុចនេះអាចមានការក្លែងបន្លំ ឬការប្រែប្រួលជាប្រតិសកម្ម ដែលអាចប៉ះពាល់ដល់ការបកស្រាយ និងតម្លៃជាភស្តុតាងនៃឯកសារនោះ។ ក្នុងករណីមានវិវាទកើតឡើង គេត្រូវអនុម័តនូវវិធានមួយចំនួនសម្រាប់ជាដំណោះស្រាយ ហើយគេយកឯកសារដើមមកប្រើប្រាស់"។

[27] *ដូចជើងទំព័រ*។

៩. នៅតុលាការ *មិនអចិន្ត្រៃយ៍* ឯកសារមួយមិនអាចជឿជាក់ពេញលេញបានទេ នៅពេលដែលអានុភាពនៃភាពលម្អៀងស្តីពីភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី មានទម្ងន់ជាងតម្លៃជាភស្តុតាង[28]។ នៅតុលាការ ICTY គោលការណ៍នេះត្រូវបានចងក្រងយ៉ាងទូលំទូលាយ[29] តែអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR និងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនបានយកគោលការណ៍នេះមកអនុវត្ត ដោយផ្អែកលើអំណាចឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយរបស់ខ្លួន ដើម្បីសម្រេចពីភាពដែលអាចទទួលយកបាន ដោយផ្អែកលើភាពពាក់ព័ន្ធ និងតម្លៃជាភស្តុតាងនៃឯកសារ[30]។ ដោយផ្អែកលើសេចក្តីត្រូវការ ក្នុងការធានាពីសិទ្ធិក្នុងការទទួលយុត្តិធម៌របស់ជនជាប់ចោទនោះ យុត្តិសាស្ត្រនៃតុលាការសម្រេចថា "អង្គជំនុំជម្រះនេះមានអំណាចក្នុងការដកចេញភស្តុតាង ប្រសិនបើអានុភាពនៃភាពលម្អៀងមានទម្ងន់ជាងតម្លៃជាភស្តុតាងនៃឯកសារនោះ ឬ ប្រសិនបើអានុភាពនោះមានទម្ងន់ជាងសេចក្តីត្រូវការ ក្នុងការធានាឲ្យបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌"[31]។

---

[28] ឧទាហរណ៍ "ដើម្បីជាប្រយោជន៍នៃសវនាការយុត្តិធម៌" អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Kvočka* បានសម្រេចដោយដកចេញនូវអត្ថបទដកស្រង់មួយពីអត្ថបទសារព័ត៌មានអំពីជំរំ Omarška ដោយសារតម្លៃជាភស្តុតាងរបស់អត្ថបទនោះមានកម្រិតទាប ដោយសារវាមានការចោទប្រកាន់ដែលពុំមានសំអាងហេតុគ្រប់គ្រាន់ ទាក់ទិននឹងជំរំនោះ ហើយ "លក្ខណៈបែបវាយប្រហារនៃការចោទប្រកាន់ទាំងនោះមានភាពលម្អៀងខ្លាំងពេក ដែលធ្វើឲ្យមេធាវីការពារក្តីយល់ថា ចំណុចនេះមានទម្ងន់ជាងតម្លៃជាភស្តុតាងដែលអត្ថបទនោះគួរមាន"។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kvočka *និងអ្នកដទៃទៀត,* សំណុំរឿងលេខ IT-98-30/1-T, សេចក្តីសម្រេចលើវត្ថុតាង, ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០១, ទំព័រ ២។

[29] វិធាន ៨៩(ឃ) នៃវិធាននីតិវិធី និង ភស្តុតាងរបស់តុលាការ ICTY ចែងថា៖ "អង្គជំនុំជម្រះអាចដកភស្តុតាងចេញបាន ប្រសិនបើតម្រូវការនៃការធានាឲ្យមានសវនាការយុត្តិធម៌ មានទម្ងន់ខ្លាំងជាងតម្លៃជាភស្តុតាងរបស់វានោះ"។

[30] *សូមមើល* វិធាន ៧០(ច) នៃវិធាននីតិវិធី និង ភស្តុតាងរបស់តុលាការ ICTR ចែងថា៖ "មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងអនុវិធាន [៧០](គ) ឬ [៧០](ឃ) ខាងលើត្រូវមានឥទ្ធិពលទៅលើអំណាចរបស់អង្គជំនុំជម្រះតាមវិធាន ៨៩(គ) ក្នុងការដកចេញភស្តុតាងបានទេ ប្រសិនបើ តម្រូវការនៃការធានាឲ្យមានសវនាការយុត្តិធម៌ មានទម្ងន់ខ្លាំងជាងតម្លៃជាភស្តុតាងរបស់វានោះ"។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Karemera *និងអ្នកដទៃទៀត,* សំណុំរឿងលេខ ICTR-98-44-T, សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឲ្យទទួលយកជាភស្តុតាងនូវការសម្ភាសន៍ជាមួយ Joseph Nzirorera និង Mathieu Ngirumpatse ក្រោយពេលចាប់ខ្លួន, ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០០៧, កថាខណ្ឌ ៣។ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង* *Norman et al.*, SCSL-2004-14-T។ សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឲ្យទទួលយកជាភស្តុតាងនូវឯកសារជាក់លាក់មួយចំនួន ដោយអនុលោមទៅតាមវិធាន៩២ *ស្អួន* និងវិធាន៨៩ (គ) ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៥ កថាខណ្ឌ ៣។

[31] *សូមមើលជាឧទាហរណ៍, រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Karemera *និងអ្នកដទៃទៀត,* សំណុំរឿងលេខ ICTR-98-44-T, សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឲ្យទទួលយកជាភស្តុតាងនូវការសម្ភាសន៍ជាមួយ Joseph Nzirorera និង Mathieu

## គ. ភាពមិនអាចទទួលយកបាននៃចម្លើយនានាដែលធ្វើឡើងដោយមានការជំរុញទឹកចិត្ត ដោយការបង្ខំ ឬដោយការគំរាមកំហែង

១០. វិធាន២១(៣) នៃវិធានផ្ទៃក្នុងចែងថា៖ "គ្មានទម្រង់ណាមួយនៃការជំរុញទឹកចិត្ត ការបង្ខំលើរាងកាយ ឬការគំរាមកំហែង ត្រូវបានយកទៅអនុវត្ត ក្នុងពេលធ្វើសម្ភាសន៍ ចំពោះអ្នកដែលត្រូវបានសួរយកចម្លើយ ឬអ្នកដទៃទៀតឡើយ។ ប្រសិនបើទម្រង់ណាមួយនៃស្ថានភាពទាំងនេះ ត្រូវបានប្រើប្រាស់នោះ ចម្លើយ ឬកំណត់ហេតុមិនត្រូវចាត់ទុកជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះឡើយ"។ អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០១[32] និងទាំងអង្គបុរេជំនុំជម្រះ[33] និងអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២[34] បានយកមកអនុវត្តនូវគោលការណ៍នេះ ដោយអង្គជំនុំជម្រះសាលាដំបូងបានសម្រេចក្នុងសំណុំរឿង ០០១ ថា ដោយអនុលោមតាមវិធាន ២១(៣) "ចំណុចនេះមានន័យថា ចម្លើយសារភាពដែលបានធ្វើឡើង ហើយបានធ្វើឡើងក្រោមការធ្វើទារុណកម្មនោះ គឺជាអង្គហេតុដែលទទួលយកបាន។ ប៉ុន្តែខ្លឹមសារនៃការសារភាព ដែលធ្វើឡើង

---

Ngirumpatse ក្រោយពេលចាប់ខ្លួន, ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០០៧, កថាខណ្ឌ ៣។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bagosora និងអ្នកដទៃទៀត,* សំណុំរឿងលេខ ICTR-98-41- AR93 & ICTR-98-41-AR93.2, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់រដ្ឋអាជ្ញាទាក់ទិននឹងការដកភស្តុតាងចេញ, ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៣, ពីកថាខណ្ឌ ១៦ ដល់កថាខណ្ឌ ១៧៖ "អង្គជំនុំជម្រះសាលាដំបូងអាចដកចេញភស្តុតាងដែលពាក់ព័ន្ធ និង មានតម្លៃជាភស្តុតាងបាន នៅពេលដែលអានុភាពនៃភាពលម្អៀងរបស់ភស្តុតាងនេះប៉ះពាល់ដល់ភាពយុត្តិធម៌ ឬ ភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី ...។ វិធីសាស្ត្រដែលត្រឹមត្រូវនោះគឺ ត្រូវថ្លឹងថ្លែងពីតម្លៃជាភស្តុតាងរួមរបស់ភស្តុតាងជាក់លាក់ណាមួយ ទល់នឹងអានុភាពនៃភាពលម្អៀងរួមរបស់វា"។

[32] *សំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ ឌុច* 001/ 18-07-2007/ECCC/TC, ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារលេខ E1/22.1, ERN: 00338970 ទំព័រ៦។ *សំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ ឌុច* 001/ 18-07-2007/ECCC/TC, ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារលេខ E1/27.1, ERN: 00336854 ទំព័រ៩។

[33] សេចក្តីសម្រេចលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មត ក.ស.ច.ស ទៅលើសំណើរបស់អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ឯកសារលេខ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារលេខ D130/7/3/5 កថាខណ្ឌ ៣៨។

[34]ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើលេខ E67, E57, E56, E58, E23, E59, E20, E33, E71និងE73 បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១, ថ្ងៃទី ៨ ខែ មេសា ឆ្នាំ២០១១ ឯកសារលេខ E74 ទំព័រ ៣។

ដោយទារុណកម្មនោះ គឺមិនអាចទទួលយកបានថាជាចម្លើយមួយដែលពិតប្រាកដនោះទេ”[35]។ ប្រហាក់ប្រហែលគ្នានេះដែរ វិធានដែលធ្វើការច្រានចោលភស្តុតាង ដែលមានលក្ខណៈផ្ទុយទៅនឹងសុចរិតភាពនៃដំណើរការនីតិវិធី ឬដែលធ្វើឲ្យខូចកិត្តិសព្ទរដ្ឋបាលយុត្តិធម៌ ឬដែលទទួលបានតាមរយៈការបង្ខិតបង្ខំ ឬការបំពារបំពានសិទ្ធិមនុស្ស គឺអាចអនុវត្តទៅបាននៅតុលាការកម្ពុជាទូទៅ[36] និងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ[37]។

## ៣. ភាពពាក់ព័ន្ធ

១១. ភាពពាក់ព័ន្ធរបស់ឯកសារមួយត្រូវតែកំណត់មុនការទទួលយកឯកសារនោះជាភស្តុតាង (ដើម្បីជៀសវាងការទទួលយកឯកសាររាប់មិនអស់ ដែលមិនអាចបង្ហាញថាពាក់ព័ន្ធ ឬភ្ជាប់ទៅនឹងបញ្ហាពាក់ព័ន្ធណាមួយ បរិបទ ឬអ្វីផ្សេង)។ ភាពពាក់ព័ន្ធអាចត្រូវបានកំណត់ថាជា “ភស្តុតាង ដែលទំនងគាំទ្រ ឬបដិសេធបញ្ហាសម្ភារៈ៖ ឬនិយាយម្យ៉ាងទៀតថា ភស្តុតាងគឺពាក់ព័ន្ធ ‘ប្រសិនបើអានុភាពរបស់វាធ្វើឲ្យអត្ថិភាពនៃអង្គហេតុណាមួយក្នុងបញ្ហាដែលកំពុងចោទ មានលក្ខណៈគួរឲ្យជឿជាក់កាន់តែតិច ឬកាន់តែច្រើន ខ. ជាធាតុផ្សំដែលសម្រេចលើពិរុទ្ធភាព ឬភាពគ្មានទោស”[38]។ យោងតាមពាក្យពេចន៍របស់ចៅក្រម Mohammed Shahabuddeen នៅអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY/ICTR៖ “ភស្តុតាងត្រូវតែពាក់ព័ន្ធ នេះចង់មានន័យថា វាចាំបាច់ត្រូវធ្វើឲ្យអង្គ

---

[35] *សំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ ឌុច* 001/ 18-07-2007/ECCC/TC, ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារលេខ E1/27.1, ERN: 00336854 ទំព័រ៩។

[36] CPC មាត្រា៣២១: “ចម្លើយសារភាពមួយត្រូវបានពិចារណាដោយតុលាការ តាមវិធីដូចគ្នានឹងភស្តុតាងផ្សេងៗទៀតដែរ។ សេចក្តីប្រកាស ដែលធ្វើឡើងក្រោមរូបភាពនៃការបង្ខិតបង្ខំផ្នែកអារម្មណ៍ និងផ្លូវកាយ គ្មានតម្លៃជាភស្តុតាងអ្វីសោះឡើយ”។

[37] សូមមើល វិធាន៩៥ នៃវិធាននៃនីតិវិធី និងភស្តុតាងនៅតុលាការ ICTY និង ICTR “គ្មានភស្តុតាងណាមួយនឹងត្រូវទទួលយកបានទេ ប្រសិនបើភស្តុតាងនោះទទួលបានពីការប្រើប្រាស់វិធីសាស្ត្រនានា ដែលធ្វើឲ្យមានវិមតិសង្ស័យលើភាពគួរឲ្យជឿជាក់បានរបស់វា ឬប្រសិនបើការទទួលយកភស្តុតាងនោះមានលក្ខណៈផ្ទុយ ហើយនឹងធ្វើឲ្យខូចខាតធ្ងន់ធ្ងរដល់សុចរិតភាពនៃដំណើរការនីតិវិធី”។ វិធាន៩៥នៃវិធាននៃនីតិវិធី និងភស្តុតាងនៅតុលាការ SCSL ចែងថា “គ្មានភស្តុតាងណាមួយនឹងត្រូវទទួលយកបានទេ ប្រសិនបើការទទួលយកនេះធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើកេរ្តិ៍ឈ្មោះរបស់រដ្ឋបាលយុត្តិធម៌”។ មាត្រា៦៩(៧)នៃលក្ខន្តិកៈតុលាការ ICC ចែងថា “ភស្តុតាងមិនត្រូវទទួលយកបានទេ” នៅពេលដែលភស្តុតាងនោះ “ទទួលបានដោយមធ្យោបាយនៃការបំពារបំពានលក្ខន្តិកៈនេះ ឬសិទ្ធិមនុស្សដែលទទួលស្គាល់ជាអន្តរជាតិ” ឬ “ការបំពារបំពានដែលធ្វើឲ្យមានវិមតិសង្ស័យលើភាពគួរឲ្យជឿជាក់បាននៃភស្តុតាងនោះ” ឬ “ការទទួលយកភស្តុតាងនោះមានលក្ខណៈបញ្ច្រាសនឹង ហើយនឹងធ្វើឲ្យខូចខាតធ្ងន់ធ្ងរដល់សុច្ចរិតភាពនៃដំណើរការនីតិវិធី”។

[38] MAY & WIERDA, ទំព័រ១០២។

ហេតុមួយគួរឲ្យជឿជាក់បាន ដែលត្រូវតែបង្កើតឲ្យមាននៅពេលជំនុំជម្រះ តែប្រសិនបើវាមិនពាក់ព័ន្ធទេនោះ លក្ខណៈមិនពាក់ព័ន្ធតែមួយគត់ គឺគ្រប់គ្រាន់សម្រាប់បដិសេធភស្តុតាងនោះចោលបានហើយ”[39]។ ឯកសារមួយដែលមិនជាប់ពាក់ព័ន្ធអាចត្រូវបានសម្រេចថា មិនអាចទទួលយកបានដោយអនុលោមតាមវិធាន៨៧(៣)(ក)[40]។

## II. ឧត្តមានុភាពករណ៍

### ក. ជំហានដែលត្រូវអនុវត្តនៅពេលពិចារណាការទទួលយកភស្តុតាង

១២. លក្ខខណ្ឌតម្រូវនៃយថាភាព ភាពគួរឲ្យជឿជាក់បាន និងភាពពាក់ព័ន្ធ ចាំបាច់ត្រូវពិចារណា នៅពេលកំណត់ថាតើឯកសារនោះអាចត្រូវបានទទួលយកជាភស្តុតាងក្នុងសំណុំរឿង ០០២ ឬយ៉ាងណា។ មូលដ្ឋានសម្រាប់លក្ខខណ្ឌតម្រូវទាំងនេះគឺស្របតាមតក្កវិជ្ជារបស់អាវីស្តូត ដែលថា៖ ល្គិកណា និងលុះត្រាណា ឯកសារដែលកំពុងត្រូវបានទទួលយកជាផ្លូវការ ត្រូវបានចាត់ទុកថា មានគុណភាពជាក់លាក់នៃភាពគួរឲ្យជឿទុកចិត្ត ឯកសារនោះពុំគួរត្រូវបានពិចារណាឡើយ។ តាមន័យនេះ នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃភស្តុតាង មេធាវីការពារក្តីសូមស្នើឲ្យពិចារណាលើជំហានខាងក្រោម៖

<u>ទីមួយ</u> ការសម្រេចមួយត្រូវតែធ្វើឡើងជាចាំបាច់ ដើម្បីកំណត់ថាតើឯកសារនោះ គឺជាឯកសារដែលមានយថាភាព ឬមិនមាន។ ប្រសិនបើឯកសារនោះមិនមានយថាភាពនោះទេ គេពុំគួរពិចារណាទៅលើឯកសារនោះឡើយ។ ឧទាហរណ៍ ប្រសិនបើ ក.ស.ព ទទួលយកជាផ្លូវការនូវ “កំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍” ល្គិកណាតែកំណត់ហេតុប្រជុំទាំងនេះ ត្រូវបានបញ្ជាក់អំពីយថាភាព បើមិនដូច្នេះទេឯកសារទាំងនេះពុំគួរមានតម្លៃអ្វីទាំងអស់ ហើយព័ត៌មានទាំងអម្បាលម៉ាននៅក្នុងឯកសារទាំងនេះគួរចាត់ទុកថា ជាព័ត៌មានមិនគួរឲ្យទុកចិត្ត។

---

[39] *រឿងក្តី រាជអាជ្ញា តទល់នឹង Ngeze & Nahimana*, ICTR-99-52-I សេចក្តីសម្រេចលើបណ្តឹងបន្ទាន់បង្ខំ មតិយោបល់ដាច់ដោយឡែករបស់ចៅក្រម Shahabuddeen ចុះថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០០ កថាខណ្ឌ១៩។

[40] *សូមមើល* សាលក្រមជំនុំជម្រះក្នុងសំណុំរឿង *ឌុច* កថាខណ្ឌ៤១។ សេចក្តីសម្រេចក្នុងសំណុំរឿង *ឌុច* ស្តីពីភាពអាចទទួលយកសម្ភារៈនៅក្នុងសំណុំរឿង កថាខណ្ឌ៧។ សេចក្តីសម្រេចក្នុងសំណុំរឿង *ឌុច* អំពីភាពអាចទទួលយកបាននៃភស្តុតាងថ្មី កថាខណ្ឌ១៦.៤។

ទីពីរ នៅពេលដែលឯកសារត្រូវបានចាត់ទុកថាមានយថាភាពហើយនោះ ជំហានបន្ទាប់គឺគួរកំណត់ថាតើឯកសារនោះគួរឲ្យជឿជាក់បាន ឬមិនគួរឲ្យជឿជាក់បានទេ។ ឧទាហរណ៍សន្មតថា "កំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍" មានយថាភាព ដូច្នេះវាគួរត្រូវបានកំណត់ថា ឯកសារទាំងនោះស្ថិតក្នុងទម្រង់ដើមរបស់វា។

ទីបី នៅពេលដែលឯកសារនោះត្រូវបានកំណត់ថាមានយថាភាព និងគួរឲ្យជឿជាក់បាន ជំហានបន្ទាប់គឺត្រូវកំណត់ ថាតើវាពាក់ព័ន្ធនឹងបញ្ហាណាមួយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬមិនពាក់ព័ន្ធ។ ប្រសិនបើឯកសារត្រូវបានចាត់ទុកថាមិនពាក់ព័ន្ធនោះទេ ឯកសារនោះមិនគួរនឹងទទួលយក ឬពិចារណាឡើយ ទោះបីជាឯកសារនោះមានយថាភាព និងគួរឲ្យជឿជាក់បានក៏ដោយ។

### ខ. ចំណាត់ថ្នាក់នៃឯកសារ ដែលមិនអាចទទួលយកបាន

១៣. ដោយពិចារណាទៅលើកម្រិតអប្បបរមានៃយថាភាព ភាពគួរឲ្យជឿជាក់ និងភាពពាក់ព័ន្ធ ចំណាត់ថ្នាក់នៃឯកសារខាងក្រោម (ដូចបានរៀបរាប់ដោយភាគីក្នុងបញ្ជីឈ្មោះឯកសាររបស់ខ្លួន) បង្កើតឲ្យមានការព្រួយបារម្ភកាន់តែធ្ងន់ធ្ងរ ទាក់ទិននឹងភាពទទួលយកបាននៃឯកសារទាំងនេះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង៖

### ១. ឯកសារទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា

១៤. មេធាវីការពារក្តីសូមយោងទៅដល់សំណើផ្លូវច្បាប់មុនៗរបស់ខ្លួន ស្តីពីភាពទទួលយកបាននៃឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជា[41] ដែលបង្ហាញថា យថាភាពនៃឯកសារបានមកពីមជ្ឈមណ្ឌល

[41] *សូមមើល* ចម្លើយតបរបស់លោក អៀង សារី ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឲ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ E96/3 កថាខណ្ឌ២២-២៤។ សារណារបស់លោក អៀង សារី ប្រឆាំងនឹងការប្រើប្រាស់សម្ភារៈទាំងអស់ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូល ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E59។ ពាក្យសុំរបស់លោក អៀង សារី ស្នើឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពលើភស្តុតាងទាំងអស់ ដែលប្រមូលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារលេខ D387។ បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់ក.ស.ច.ស សម្រេចបដិសេធសំណើរបស់គាត់ សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃៈភាពកិច្ចស៊ើបសួរ ដែលធ្វើឡើងដោយ ឬដោយមានជំនួយពីលោក Boyle និង លោក Heder និងសំណើរបស់លោក អៀង សារី សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃៈភាពភស្តុតាងទាំងឡាយ ដែលប្រមូលពីមជ្ឈមណ្ឌលឯកសារកម្ពុជា និង

ឯកសារកម្ពុជាមិនអាចត្រូវបានផ្ទៀងផ្ទាត់ឡើងវិញបានឡើយ។ ឯកសារបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា មានពាក់ព័ន្ធនឹងភាពលម្អៀង។ គោលជំហររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺថា មានការប្រល័យពូជសាសន៍នៅកម្ពុជា។ តួនាទីនេះបានធ្វើឱ្យខ្លួនខិតខំប្រមែប្រមូលឯកសារនានា ដើម្បីគាំទ្រការអះអាងនេះ។ អានុភាពនៃភាពលម្អៀងនៃឯកសារបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាលើភាពត្រឹមត្រូវនៃដំណើរការនីតិវិធីមានទម្ងន់ជាងតម្លៃជាភស្តុតាងរបស់វា ហើយឯកសារបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាមានលក្ខណៈមិនអាចជឿជាក់បាន និងមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាងឡើយ។ អង្គជំនុំជម្រះសាលាដំបូងគួរច្រានចោលសំណើសុំឱ្យទទួលយកឯកសារបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយអនុលោមតាមវិធាន ៨៧(៣)(ខ)។

## ២. ឯកសារទទួលបានពីកម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជា (CGP)

១៥. ចាប់តាំងពីឆ្នាំ ១៩៩៤ មក កម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជា ជាគម្រោងមួយរបស់កម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅមជ្ឈមណ្ឌល MacMillan សម្រាប់ការសិក្សាស្រាវជ្រាវតំបន់ និងអន្តរជាតិនៃមហាវិទ្យាល័យ Yale បានសិក្សាអំពីព្រឹត្តិការណ៍នានាដែលកើតឡើងនៅប្រទេសកម្ពុជានៅចន្លោះឆ្នាំ១៩៧៥-៧៩ "ដើម្បីជួយកំណត់ថាតើនរណាជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាក្នុងរបប ប៉ុល ពត"[42]។ កម្មវិធីនេះសន្មតជាមុនថា មានការប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា[43] ដូច្នេះហើយ ឯកសារបានពីកម្មវិធីនេះ គឺជិតដាមដោយភាពលម្អៀង។ អានុភាពនៃភាពលម្អៀងនៃ ឯកសារបានពីកម្មវិធីនេះទៅលើភាពត្រឹមត្រូវនៃដំណើរការនីតិវិធីមានទម្ងន់ជាងតម្លៃជាភស្តុតាងរបស់វា ហើយឯកសារបានពីកម្មវិធីនេះមានលក្ខណៈមិនអាចជឿជាក់បាន និងមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាងឡើយ។ អង្គជំនុំជម្រះសាលាដំបូងគួរច្រានចោលសំណើសុំឱ្យទទួលយក ឯកសារបានមកពីកម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជា ដោយអនុលោមតាមវិធាន៨៧(៣)(ខ)។

## ៣. សម្ភារៈទទួលបានដោយការិយាល័យសហព្រះរាជអាជ្ញា

---

បណ្តឹងឧទ្ធរណ៍ភ្លាមៗប្រឆាំងនឹងការបដិសេធរបស់ ក.ស.ច.ស លើការផ្អាកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D402/1/2។

[42] *សូមមើល* គេហទំព័រ CGP ដែលអាចរកមើលបាននៅ http://www.yalc.cdu/cgp/ ។

[43] ដូចជើងទំព័រខាងលើ។

១៦. មេធាវីការពារក្តីសូមយោងទៅដល់សំណើផ្លូវច្បាប់មុនៗរបស់ខ្លួន ស្តីពីភាពទទួលយកបាននៃសម្ភារៈទទួលបានដោយការិយាល័យសហព្រះរាជអាជ្ញា (ដូចជា កំណត់ហេតុស្តាប់ចម្លើយសាក្សីសៀវភៅ និងអត្ថបទសារព័ត៌មាន)[44]។ ការស្តាប់ចម្លើយ ដែលធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញា និងឯកសារនានា ដែលប្រមូលពីអ្នកតាក់តែង ដែលមានជាប់ពាក់ព័ន្ធនឹងការិយាល័យសហព្រះរាជអាជ្ញា (ដូចជា លោកបណ្ឌិត Craig Etcheson) គឺជិតដាមដោយភាពលម្អៀងក្នុងតួនាទីជាការិយាល័យសហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៨៧(១) ក្នុងការបង្ហាញពិរុទ្ធភាពរបស់លោក អៀង សារី។ អានុភាពនៃភាពលម្អៀងនៃសម្ភារៈទទួលបានដោយការិយាល័យសហព្រះរាជអាជ្ញាលើភាពត្រឹមត្រូវ នៃដំណើរការនីតិវិធីមានទម្ងន់ជាងតម្លៃជាភស្តុតាងរបស់វា។ សម្ភារៈដែលទទួលបានដោយការិយាល័យសហព្រះរាជអាជ្ញា មានលក្ខណៈមិនអាចជឿជាក់បាន និងមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង។ អង្គជំនុំជម្រះសាលាដំបូងគួរច្រានចោលសំណើសុំឲ្យទទួលយកសម្ភារៈទទួលបានដោយការិយាល័យសហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន ៨៧(៣)(ខ)។

### ៤. សម្ភារៈដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម

១៧. មេធាវីការពារក្តីសូមយោងទៅដល់សំណើផ្លូវច្បាប់មុនៗរបស់ខ្លួន ស្តីពីភាពទទួលយកបាននៃសម្ភារៈដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម[45]។ សម្ភារៈដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម

---

[44] *សូមមើល* ចម្លើយតបរបស់លោក អៀង សារី ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៩២ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឲ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ E96/3 កថាខណ្ឌ២៥។ បន្ថែមលើនេះទៀត "ដោយយកមកពិចារណាថា ក្នុងដំណាក់កាលស៊ើបអង្កេត រដ្ឋអាជ្ញាតែងតែប្រកាន់នូវគោលជំហរសង្កត់ – អាស្រ័យទៅលើមធ្យោបាយនៅខណៈនៃការប្រើប្រាស់អំណាចតាមចិត្តរបស់ខ្លួន ក្នុងការប្រមូលព័ត៌មាននៅមុនពេលជំនុំជម្រះ – ធ្វើបៀបនេះ គឺដើម្បីបង្កើតឡើងវិញនូវសមភាព ដែលវាចាំបាច់ត្រូវហាមប្រាមនូវសេចក្តីថ្លែងការណ៍ដែលពុំអាចសួរដេញដោលបានទាំងអស់ដែលគេប្រមែប្រមូលបាន ក្នុងដំណាក់កាលនោះ យកមកប្រើប្រាស់ធ្វើជាភស្តុតាង"។ Michele Caianiello *សេចក្តីសម្រេចដំបូងស្តីពីការទទួលយកភស្តុតាងនៅក្នុងការជំនុំជម្រះនៅតុលាការ ICC*, 9 J. INT'L CRIM. JUST. 385, 390 (ឆ្នាំ២០១១)។

[45] *សូមមើល* សំណើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការប្រើប្រាស់ភស្តុតាង ដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្មនៅក្នុងពេលជំនុំជម្រះ ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E33។ សំណើសុំទាក់ទងនឹងការទទួលស្គាល់របស់ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាង ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារលេខ D130/7។ សំបុត្រទាក់ទងនឹងការទទួលស្គាល់របស់ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាង ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០០៩ ឯកសារលេខ D/130/7/21។ បណ្តឹង

ក្រោមទម្រង់ទាំងអស់របស់វា និងក្នុងគ្រប់កាលៈទេសៈ (លើកលែងតែប្រឆាំងនឹងអ្នកដែលត្រូវបានចោទពីការធ្វើទារុណកម្ម ធ្វើជាភស្តុតាងបញ្ជាក់ថា សេចក្តីថ្លែងការណ៍ត្រូវបានធ្វើឡើង) ពុំអាចទទួលយកបានទេ ក្នុងដំណើរការនីតិវិធីរបស់តុលាការនៅចំពោះមុខអ.វ.ត.ក[46]។ នេះរាប់បញ្ចូលទាំងសម្ភារៈបន្ទាប់បន្សំ (រួមមាន ព័ត៌មានទាក់ទងនឹងប្រវត្តិរូបបឋម និងភស្តុតាងដែលកើតចេញពីចម្លើយសារភាពផ្សេងៗទៀត)[47] ដែលកើតចេញពីសម្ភារៈ ដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម។ សម្ភារៈ ដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម មិនត្រូវបានអនុញ្ញាតឡើយ ក្រោមច្បាប់ ហើយវា

---

ឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្និតរបស់ក.ស.ច.សទៅលើសំណើរបស់ អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាង ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារលេខ D130/7/3/1។ ការឆ្លើយតបរបស់ អៀង សារី ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្និតរបស់ កសចស នូវសំណើសុំរបស់ អៀង សារី ទាក់ទងនឹងការទទួលស្គាល់ និងការសំអាងរបស់ កសចស ទៅលើភស្តុតាង ដែលបានមកតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ឯកសារលេខ D130/7/3/4។

46 សូមមើលអនុសញ្ញាអន្តរជាតិស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលត្រូវបានអនុម័ត និងដាក់ឲ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន និងការចូលជាសមាជិក ដោយសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៣៩/៤៦ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៤ (កម្ពុជាចូលជាសមាជិក ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២)។ មាត្រា១៥៖ រដ្ឋភាគីត្រូវធានាថា ឯកសាររាយការណ៍ទាំងឡាយ ដែលបង្កើតឡើងបានមកពីអំពើទារុណកម្ម មិនត្រូវយកមកសំអាងជាធាតុនៃភស្តុតាងក្នុងនីតិវិធីណាមួយឡើយ លើកលែងតែឯកសាររាយការណ៍នោះ ត្រូវបានធ្វើសម្រាប់ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទនៃអំពើទារុណកម្ម។ *សូមមើល* CPC មាត្រា៣២១៖ “...ចម្លើយសារភាពមួយត្រូវបានពិចារណាដោយតុលាការ តាមវិធីដូចគ្នានឹងភស្តុតាងផ្សេងៗទៀតដែរ។ សេចក្តីប្រកាស ដែលធ្វើឡើងក្រោមរូបភាពនៃការបង្ខិតបង្ខំផ្នែកអារម្មណ៍ និងផ្លូវកាយ គ្មានតម្លៃជាភស្តុតាងអ្វីសោះឡើយ”។ *ក៏សូមមើល* អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប បានអនុម័ត និងបើកឲ្យចុះហត្ថលេខា ឲ្យសច្ចាប័ន និងឲ្យចូលជាសមាជិក តាមសេចក្តីសម្រេចចិត្តលេខ ៣៩/៤៦ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៤ មាត្រា១៥ “រដ្ឋភាគីត្រូវធានាថា ឯកសាររាយការណ៍ទាំងឡាយ ដែលបង្កើតឡើងបានមកពីអំពើអារុណកម្ម មិនត្រូវយកមកសំអាងជាធាតុនៃភស្តុតាងក្នុងនីតិវិធីណាមួយឡើយ លើកលែងតែឯកសាររាយការណ៍នោះ ត្រូវបានធ្វើសម្រាប់ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទនៃអំពើទារុណកម្ម”។

47 *សូមមើល* សំណើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការប្រើប្រាស់ភស្តុតាង ដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម នៅក្នុងពេលជំនុំជម្រះ ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E33 កថាខណ្ឌ ១៧-២៣។ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្និតរបស់ក.ស.ច.សទៅលើសំណើរបស់ អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាង ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារលេខ D130/7/3/1 កថាខណ្ឌ ២៧-៣៣។

មានលក្ខណៈមិនអាចជឿជាក់បាន។ អង្គជំនុំជម្រះសាលាដំបូងគួរច្រានចោលសំណើសុំទទួលយកសម្ភារៈដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម ដោយអនុលោមតាមវិធាន៨៧(៣)(ឃ)។

**៥. របាយការណ៍ អត្ថបទ និងឯកសារនានាដែលមិនបានបន្សល់ទុកពីសម័យនោះ**

១៨. នៅតុលាការ *មិនអចិន្ត្រៃយ៍*នានា របាយការណ៍សារព័ត៌មាន "ជាទូទៅ មិនត្រូវបានចាត់ទុកជាប្រភពដែលអាចជឿជាក់បាននៃភស្តុតាង ហើយជាញឹកញាប់ត្រូវបានផាត់ចេញដោយកង្វះតម្លៃជាភស្តុតាង"[48]។ ភាពទទួលយកបាននៃរបាយការណ៍ទាំងនេះអាស្រ័យទៅលើកាលៈទេសៈនៃឱកាសជាក់លាក់មួយ និងសារៈសំខាន់នៃភស្តុតាង[49]។ វានឹងមានលក្ខណៈមិនធម្មតា ដែលភស្តុតាងបែបនេះត្រូវបានទទួលយក ប្រសិនបើវាពាក់ព័ន្ធនឹងបញ្ហាសំខាន់មួយក្នុងសំណុំរឿង ប៉ុន្តែវាទំនងត្រូវបានទទួលយកច្រើនជាង ប្រសិនបើវាទាក់ទិននឹងបញ្ហាបរិបទ[50]។ តម្លៃជាភស្តុតាងនៃរបាយការណ៍ និងអត្ថបទសារព័ត៌មានមួយចំនួន អាចមានទម្ងន់ស្រាលជាង អានុភាពនៃភាពលម្អៀងរបស់វាទៅលើភាពត្រឹមត្រូវនៃដំណើរការនីតិវិធី[51]។ ឯកសារបែបនេះមិនអាចជឿជាក់

---

[48] MAY & WIERDA, ទំព័រ២៤៨ *លើកឡើងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kvočka *និង អ្នកដទៃទៀត*. សំណុំរឿងលេខ IT-98-30/1-T សេចក្តីសម្រេចលើវត្ថុតាង ចុះថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ ២០១១។

[49] MAY & WIERDA ទំព័រ២៤៨។ ក៏សូមមើល Gosnell, ទំព័រ៤០៨-០៩: "របាយការណ៍ពីប្រព័ន្ធផ្សព្វផ្សាយត្រូវបានគេយល់ថាពោរពេញទៅដោយភាពគួរឱ្យជឿជាក់បានមិនលក្ខណៈច្បាស់លាស់។ ស្តង់លក់កាសែតក្នុងស្រុកខ្លះគ្រាន់តែជាវេទិកាសម្រាប់ឃោសនាប៉ុណ្ណោះ ដែលរបាយការណ៍របស់ពួកគេ ដូចអង្គជំនុំជម្រះមួយបានមានយោបល់ថា "ល្បីល្បាញក្នុងនាមជាខ្ញុំបម្រើនៃទឹកចិត្ត ជាជាងខ្ញុំបម្រើនៃការពិត"។ សូម្បីតែអាជីពសារព័ត៌មានសត្យានុម័តភាគច្រើន ជាញឹកញាប់ ពឹងផ្អែកជ្រុលទៅលើចម្លើយសារភាពនៃប្រភពមិនច្បាស់លាស់ ដែលធ្វើឱ្យមានពាក្យចចាមអារ៉ាមទ្វេ ឬត្រីដង"។ ក្នុងបរិបទមួយទៀត អង្គជំនុំជម្រះតុលាការកំពូល នៅតុលាការ ICTY បានព្រមានប្រឆាំងនឹងការពឹងអាស្រ័យទៅលើព័ត៌មានបែបនេះ។ ការទទួលយករបាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយជាភស្តុតាង ដោយពុំតម្រូវឱ្យមានសក្ខីកម្មពីអ្នកសារព័ត៌មានទាំងនោះ មានន័យថាខ្លឹមសារដែលត្រូវបានដាក់បញ្ចូលទៅក្នុងកំណត់ហេតុ ដោយពុំមានការផ្ទៀងផ្ទាត់ប្រភពបន្ថែមអ្វីសោះ។ គ្មានការរើសអើងទំនងជាកើតមានឡើយ អំពីលក្ខណៈនៃរបាយការណ៍ទាំងនេះ រីឯភាពមិនច្បាស់លាស់អាចក្លាយទៅជាមានសារៈសំខាន់យ៉ាងខ្លាំង នៅពេលដែលការប្រព្រឹត្តិនោះមានលក្ខណៈជាក់លាក់ និងមានលក្ខណៈដាក់បន្ទុក និងអាចមិនក្លាយជាកម្មវត្ថុនៃការគួសបញ្ជាក់ ឬបដិវាទកម្មដោយប្រភពផ្សេងៗទៀត។ អង្គជំនុំជម្រះខ្លះបានឆ្លើយតបទៅនឹងការព្រួយបារម្ភទាំងនេះ ដោយចាត់ទុករបាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយដែលបន្សល់ទុកពីសម័យនេះជាភស្តុតាងឯកសារ ប៉ុន្តែបន្ទាប់មកផាត់ចោលភស្តុតាងទាំងនោះ ដោយមិនស្របតាមលក្ខខណ្ឌនៃតម្លៃជាភស្តុតាង..."។

[50] MAY & WIERDA ទំព័រ២៤៨។

[51] *សូមមើល រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង* Kvočka *et al.*, សំណុំរឿងលេខ IT-98-30/1-T សេចក្តីសម្រេចស្តីពីវត្ថុតាង ចុះថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ ២០០១។ *ក៏សូមមើល* Nerenberg & Timmermann ទំព័រ៤៧៨ *លើកឡើងអំពីរឿងក្តី រដ្ឋអាជ្ញា*

បាន និងមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាងឡើយ ហើយជាឯកសារដែលមិនអាចទទួលយកបាន ដោយអនុលោមតាមវិធាន ៨៧(៣)(គ)។

១៩. នៅតុលាការ ICTR អត្ថបទសារព័ត៌មានដែលមិនបានបន្សល់ទុកពីសម័យនោះ ដែលសរសេរដោយសាក្សីផ្ទាល់ភ្នែកម្នាក់បួនឆ្នាំបន្ទាប់ពីព្រឹត្តិការណ៍ ត្រូវបានរកឃើញថា "មានជាប់ទាក់ទងគ្នានឹងចម្លើយសាក្សីម្នាក់" និងមិនអាចទទួលយកបាន ដោយអនុលោមតាមវិធាន ៩២*ស្ទួន* របស់តុលាការ ICTR [52]។ ក្នុងបរិបទកម្ពុជា មានការព្រួយបារម្ភធ្ងន់ធ្ងរថា បទយកការណ៍ និង/ឬ ភស្តុតាងតាម

---

*តទល់នឹង* *Lubanga*, ICC-01/04-01/06 សេចក្តីសម្រេចលើសំណើសុំរបស់តំណាងផ្នែកច្បាប់របស់ជនរងគ្រោះ a/0001/06, a/0002/06, a/0003/06, a/0407/08, a/0409/08, a0149/07 and a/0162/07 សម្រាប់ការទទួលយករបាយការណ៍ស្តាពររបស់គណៈជំនាញការស្តីពីការកេងប្រវ័ញ្ចខុសច្បាប់លើធនធានធម្មជាតិ និងទម្រង់ផ្សេងៗទៀតនៃធនធាននៃសាធារណរដ្ឋប្រជាធិបតេយ្យ កុងហ្គោ ជាភស្តុតាង ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៩ កថាខណ្ឌ៣៤ ដែលអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Lubanga* នៅតុលាការព្រហ្មទណ្ឌអន្តរជាតិច្រានចោលមិនទទួលយករបាយការណ៍នេះជាភស្តុតាង។ មានការយោងទៅលើកថាខណ្ឌមួយចំនួននៃរបាយការណ៍នេះ នៅពេលសួរដេញដោលសាក្សីជំនាញម្នាក់ ដែលពុំមែនជាអ្នកស្មេររបាយការណ៍នេះ និងជាអ្នកដែលគូសបញ្ជាក់ថា ការព្រួយបារម្ភចំពោះរបាយការណ៍នេះគឺហួសពីជំនាញរបស់ខ្លួន។ ស្មេរនៃរបាយការណ៍នេះមិនមែនជាសាក្សី ហើយខ្លឹមសារនៃរបាយការណ៍នេះក៏ពុំពាក់ព័ន្ធផ្ទាល់នឹងបទចោទប្រឆាំងនឹងជនជាប់ចោទដែរ ដូច្នេះហើយអង្គជំនុំជម្រះរកឃើញថា "ក្នុងគ្រប់កាលៈទេសៈទាំងអស់ បើថ្លឹងថ្លែងអំពីភាពពាក់ព័ន្ធតិចតួច និងតម្លៃជាភស្តុតាងកម្រិតទាបនៃរបាយការណ៍នេះ និងសក្តានុពលរើសអើងពិតប្រាកដរបស់វា អង្គជំនុំជម្រះនៅដំណាក់កាលនេះសម្រេចថា របាយការណ៍នេះពុំគួរត្រូវបានទទួលយកនោះទេ"។ ក្នុងរឿងក្តី *Milutinović* នៅតុលាការ ICTY សេចក្តីថ្លែងការណ៍ដែលបានប្រើប្រាស់ក្នុងរបាយការណ៍មួយ រៀបចំដោយអង្គការមិនមែនរដ្ឋាភិបាល ដោយឈរលើមូលដ្ឋាននៃបទសម្ភាសន៍ជនភៀសខ្លួន ដែលរត់គេចពីទីឧក្រិដ្ឋកម្ម ត្រូវបានសម្រេចថា ពុំអាចគួរឱ្យជឿជាក់បានគ្រប់គ្រាន់ ដែលនឹងត្រូវទទួលយក ដែលក្រោយមកទៀត របាយការណ៍នេះខ្លួនឯងក៏មិនត្រូវបានទទួលយកដែរ។ *សូមមើល* Gosnell ទំព័រ៤០៤-៥ *លើកឡើងនូវ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Milutinović et al.*, សំណុំរឿងលេខ IT-05-87-T សេចក្តីសម្រេចលើភស្តុតាង ដាក់ស្នើសុំតាមរយៈ Sandra Mitchell និង Frederick Abrahams ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ២១-២២។

[52] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Bagosora et al.*, សំណុំរឿងលេខ ICTR-98-41-T សេចក្តីសម្រេចលើសំណើរបស់ Ntabakuze តម្កល់ឯកសារអង្គការសហប្រជាជាតិមួយចំនួន ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ កថាខណ្ឌ៩។ សេចក្តីសម្រេចនេះបណ្តាលឱ្យមានអ្នកបញ្ចេញមតិយោបល់ម្នាក់កត់សម្គាល់ថា "កត្តាបរិបទ និងខ្លឹមសារបញ្ជាក់ពីភាពត្រឹមត្រូវនៃវិសាលភាពដ៏ទូលំទូលាយនៃវិធាន ៩២*ស្ទួន* នៅតុលាការ ICTR។ ប្រភពមិនលម្អៀង និងគួរឱ្យជឿជាក់បានមួយចំនួននៃរបាយការណ៍ និងសេចក្តីថ្លែងការណ៍ ត្រូវបានរកឃើញក្នុងបរិបទនៃប្រទេសរវ៉ាន់ដា គឺមិនដូចនៅអតីតយូហ្គោស្លាវីឡើយ។ តិចជាង ៦៥ ភាគរយនៃប្រជាជនពេញវ័យនៃប្រទេសរវ៉ាន់ដាជាអក្ខរជន បើប្រៀបធៀបទៅនឹងអត្រាលើស ៩៥ ភាគរយនៅប្រទេសបូស្នី។ ឯកសារដែលចុះហត្ថលេខាដោយអក្ខរជនម្នាក់ ជាភាសាដែលពួកគេអាចយល់បាន ទៅជាពាក្យចចាមអារ៉ាម រីឯឯកសារដែលចុះហត្ថលេខាដោយអនក្ខរជនបែរទៅជាត្រឹមត្រូវ ដូចការបកស្រាយផ្ទាល់នៅនឹងកន្លែងដែលមិនអាចផ្ទៀងផ្ទាត់បានទាំងស្រុងទៅវិញ។ បទ

វយៈការធ្វើសក្ខីកម្ម ក្នុងសំណុំរឿង គឺពុំអាចជឿទុកចិត្តបាន លម្អៀង និងមិនអាចយកមកផ្ទៀងផ្ទាត់បានឡើយ[53]។ ដោយអនុលោមតាមវិធាន ៨៤(១) លោក អៀង សារី ត្រូវទទួលបានសិទ្ធិដាច់ខាត

---

ពិសោធន៍នៅតុលាការបង្ហាញនូវភាពពុំគួរឲ្យជឿជាក់យ៉ាងច្រើននៃចម្លើយសាក្សីនៅតុលាការ ICTR។ ជាញឹកញាប់ សាក្សីជនជាតិរវ៉ាន់ដាត្អូញត្អែរ នៅពេលសួរដេញដោលអំពីចម្លើយមុនៗ ហើយថា ចម្លើយទាំងនោះមិនបានឆ្លុះបញ្ចាំងដ៏ត្រឹមត្រូវអំពីអ្វីដែលបាននិយាយផ្ទាល់មាត់ ក្នុងពេលយកចម្លើយឡើយ” Gosnell ទំព័រ៤0២- 0៣។

[53] *សូមមើល* ROELAND A. BURGLER, ភ្នែកម្ចាស់: បញ្ញាជនបដិវត្តន៍ និងភាពភ័យខ្លាចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ១-៤ (NICCOS ឆ្នាំ១៩៩0): “បើទោះជាទើបតែបោះពុម្ពភ្លាមៗក៏ដោយ ‘អង្គហេតុ’ ជាច្រើនក្នុង…រឿងរ៉ាវអំពើឃោរឃៅទៅជាខុស ឬបកស្រាយខុស។ ឧទាហរណ៍ រូបភាព ‘ពួកខ្មែរក្រហមសម្លាប់ដោយប្រើត្បូងចប’ ឬ ‘ពលកម្មដោយបង្ខំ’ និង ‘ការរៀបការដោយបង្ខំ’ ត្រូវបានបោះពុម្ពផ្សាយ, *ក្នុងចំណោមរឿងរ៉ាវផ្សេងៗទៀត* ក្នុង *Paris-Match* និង *Stern* (ទាំងពីរ ក្នុងខែ មេសា ឆ្នាំ ១៩៧៦) the *Washington Post* (8-4-1977), the London *Observer* (30-10-1977), *Time* (21-11-1977), *Newsweek* (23-1-1978) និង *Der Spiegel* (30-1-78)….។ រូបថតទាំងនេះដំបូងឡើងត្រូវបានបោះពុម្ពផ្សាយក្នុងសារព័ត៌មានថៃមួយ នៅមុនពេលបោះឆ្នោត ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ១៩៧៦ ។ មន្ត្រីស៊ើបការណ៍ថៃម្នាក់ ក្រោយមកសារភាពថា រូបថតទាំងនោះត្រូវបានសម្តែងសម្រាប់ថតនៅក្នុងទឹកដីនៃប្រទេសថៃ។ Peang Sophi ជនភៀសខ្លួនកម្ពុជា បានរាយការណ៍ថាបានឃើញវិធីសម្លាប់បែបនេះ។ តាមប្រភពស៊ើបការណ៍របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកម្នាក់ ដែលត្រូវបានគេប្រគល់រូបថតឲ្យក្នុងទឹកដីប្រទេសថៃ បាននិយាយថា គាត់ចាត់ទុករូបថតទាំងនោះថាជារូបថតក្លែងក្លាយ។ គាត់បានប្រាប់សារព័ត៌មាន *Time* និង *Washington Post* អំពីបញ្ហានេះ។ ដូចគ្នាដែរការបោះពុម្ពផ្សេងៗទៀតក៏ទទួលបានព័ត៌មានអំពីការបោះពុម្ពផ្សាយក្លែងបន្លំទាំងនេះ ប៉ុន្តែបានបដិសេធ ហើយថែមទាំងមិនបានបោះពុម្ពផ្សាយនូវលិខិតកែតម្រូវអ្វីមួយដែរ។ មានតែសារព័ត៌មាន *Washington Post* ដែលបានបោះពុម្ពផ្សាយអត្ថបទខ្លីមួយទទួលស្គាល់មន្ទិលសង្ស័យនេះ។ ជិតពីរឆ្នាំក្រោយពីការបង្ហាញរូបថតក្លែងបន្លំទាំងនេះ សារព័ត៌មាន *Newsweek* បានបោះពុម្ពផ្សាយរូបភាពទាំងនេះ ហើយថែមទាំងដាក់ទំព័រមុខទៀតផង។ នេះគ្រាន់តែជាឧទាហរណ៍មួយនៃបញ្ជីដ៏វែងនៃការបកស្រាយខុសឆ្គង និងបញ្ចេញឲ្យឃើញនូវភាពទុច្ចរិតរបស់ពួកអ្នកសារព័ត៌មានបស្ចិមប្រទេស ដែលគេស្គាល់ថាមិនប្រកាន់បក្សពួក មានការទទួលខុសត្រូវ និងម៉ត់ចត់ប៉ុណ្ណោះ។ ការបកស្រាយខុសក៏កើតមានផងដែរ តាមរយៈភាពលម្អៀងក្នុងរបាយការណ៍ជនភៀសខ្លួន ប្រភពព័ត៌មានដ៏ចម្បង…. ពាក្យចចាមអារ៉ាមក្លាយទៅជាបទពិសោធន៍ផ្ទាល់ខ្លួន…. រឿងរ៉ាវទាំងនោះ អាចត្រូវបានទិញដូរ។ ជួនកាល បទសម្ភាសន៍ដែលមានលក្ខណៈស្តង់ដារត្រូវបានប្រគល់ជូនសរសេរដោយអ្នកដែលមិនចេះទាំងសរសេរ និងអាន ហើយជួនកាល ថែមទាំងមិនចេះនិយាយភាសាខ្មែរផង…. អ្នកសារព័ត៌មានភាគច្រើនដែលទទួលខុសត្រូវបោះពុម្ពផ្សាយរឿងរ៉ាវទាំងនោះ បានជ្រើសរើសយកព័ត៌មានដែលសក្តិសមបំផុតសម្រាប់ការបោះពុម្ពផ្សាយប្រកបដោយការព្រឺព្រួច ហើយមិនខ្វល់អំពីព័ត៌មានដទៃទៀតឡើយ។ ជាញឹកញាប់ តួនាទីរបស់ពួកគេគឺមានលក្ខណៈមិនអាចពឹងផ្អែកលើបានពីព្រោះភាពលម្អៀងរបស់ពួកគេ ហើយវិធីសាស្ត្រអន់ៗ (ដូចជាសម្ភាសន៍ក្នុងវត្តមាននៃប្រធានជំរំ ឬមន្ត្រីថៃ) បញ្ហាភាសា និងឥរិយាបទមិនដឹកស្សួរ ចំពោះអ្វីដែលពួកគេឮ …. តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ប្រភេទខ្លះនៃមតិយោបល់ស្តង់ដារទូទៅអំពីរបបកម្ពុជាប្រជាធិបតេយ្យ ជិតនៅជាប់អារម្មណ៍របស់សាធារណជនទូទៅតែម្តង” (internal citations omitted). *ក៏សូមមើល* MICHAEL VICKERY, CAMBODIA: 1975-1982 29-68 (Silkworm 1999) សម្រាប់

ក្នុងការសួរដេញដោលអ្នកតាក់តែងអត្ថបទ និងរបាយការណ៍ទាំងនោះដែលមិនបានបន្សល់ទុកពីសម័យនោះ (រួមទាំងកំណត់ហេតុស្តាប់ចម្លើយ) ដែលមេធាវីការពារក្តីគូសបញ្ជាក់ថា មានជាប់ទាក់ទិននឹងចម្លើយសាក្សី ជាលក្ខខណ្ឌមួយមុននឹងការទទួលយកឯកសារទាំងនេះជាភស្តុតាង[54]។

**៦. ចម្លើយសាក្សី**

២០. មេធាវីការពារក្តីសូមយោងទៅដល់សំណើផ្លូវច្បាប់មុនៗរបស់ខ្លួន ស្តីពីភាពទទួលយកបាននៃចម្លើយសាក្សី[55]។ ដោយសារលោក អៀង សារី ពុំទទួលបានសិទ្ធិដាច់ខាតក្នុងការតទល់ជាមួយនឹងសាក្សីនោះ លោកអៀង សារី នឹងពុំមានលទ្ធភាពដើម្បីផ្ទៀងផ្ទាត់ ថាតើអ្វីដែលបានកត់ត្រានោះ **ក.**វាត្រឹមត្រូវ **ខ.**ពេញលេញ ឬយ៉ាងណានោះទេ។ ឧទាហរណ៍ ដោយសារលោក អៀង សារី ពុំទទួលបានសិទ្ធិដាច់ខាតក្នុងការតទល់ជាមួយនឹងសាក្សីនោះ មេធាវីការពារក្តីមិនអាចផ្ទៀងផ្ទាត់ឡើងវិញ ថាតើអ្វីដែលសាក្សីបាននិយាយ និងកត់ត្រានៅក្នុងចម្លើយសាក្សីនោះ ពិតជាអ្វី (ដែលសាក្សីចង់និយាយ ឬយ៉ាងណានោះទេ) ពីព្រោះមេធាវីការពារក្តីនឹងមិនមានឱកាសដើម្បីសួរដេញដោលសាក្សីនោះទេ។ បញ្ហាបកប្រែក៏អាចធ្វើឲ្យធ្វើឲ្យមានកំហុសក្នុងកំណត់ហេតុមួយផងដែរ[56]។ ដោយសារលោក អៀង សារី ពុំទទួលបានសិទ្ធិដាច់ខាតក្នុងការតទល់នឹងសាក្សី តម្លៃជាភស្តុតាងក្នុងចម្លើយសាក្សី អាចមានទម្ងន់ទាបជាង ដោយសារតែអានុភាពនៃភាពលម្អៀងទៅលើភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី។ ចម្លើយសាក្សីមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាងឡើយ និងមិនអាចទទួលយកបាន ដោយអនុលោមតាមវិធាន៨៧(៣)(គ)។

---

ការវិភាគបន្ថែមអំពីបញ្ហាភស្តុតាងបានមកពីរបាយការណ៍ អត្ថបទ និងសម្ភារៈដែលបានបន្សល់ទុកពីសម័យនោះ ដែលអះអាងថាកត់ត្រាអំពីអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

[54] *សូមមើល* ចម្លើយតបរបស់លោក អៀង សារី ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឲ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ E96/3។

[55] ដូចជើងទំព័រខាងលើ។

[56] *សូមមើល* ចម្លើយតបរបស់មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E96/5 ចុះថ្ងៃទី២២ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ២៤-៣៧។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបនានាទាក់ទងនឹងការទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១ ឯកសារលេខ E96/6 កថាខណ្ឌ៣៥។

### ៧. ប្រតិចារឹកក្នុងសំណុំរឿង ០០១

២១. ការទទួលយកប្រតិចារឹកពីសំណុំរឿង០០១ ជាភស្តុតាងក្នុងសំណុំរឿង ០០២ គឺអាស្រ័យទៅលើសិទ្ធិដាច់ខាតរបស់លោក អៀង សារី ក្នុងការតទល់នឹងសាក្សី ដែលសក្ខីកម្មរបស់ពួកគេធ្វើឡើងក្នុងសំណុំរឿង ០០១ និងដែលកំពុងស្នើសុំឲ្យទទួលយក[57]។ ដោយសារលោក អៀង សារី ពុំទទួលបានសិទ្ធិដាច់ខាតក្នុងការតទល់ជាមួយនឹងសាក្សី ប្រតិចារឹកក្នុងសំណុំរឿង ០០១ មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុ ដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាងឡើយ ហើយមិនគួរត្រូវបានទទួលយកអនុលោមតាមវិធាន ៨៧(៣)(គ)[58]។

### ៨. ឯកសារ ដែលពុំមានជាភាសាអង់គ្លេស និងភាសាខ្មែរ

២២. មេធាវីការពារក្តីពុំប្រកាន់ជំហរណាមួយឡើយ ពាក់ព័ន្ធនឹងការទទួលយកឯកសារណាមួយ មុននឹងត្រូវបានផ្តល់ជូនទាំងជាភាសាអង់គ្លេស និងឯកសារបកប្រែជាភាសាខ្មែរ និងសូមរក្សាសិទ្ធិគ្រប់យ៉ាង។

**អាស្រ័យហេតុនេះ** យោងតាមហេតុផលដែលបានលើកឡើងខាងលើ និងដោយក្តីគោរព មេធាវីការពារក្តីសូមស្នើដោយក្តីគោរពដល់អង្គជំនុំជម្រះសាលាដំបូង សូមមេត្តា៖

ក. ស្នើឲ្យភាគីបង្ហាញអំពីយថាភាព ភាពគួរឲ្យជឿជាក់បាន និងភាពពាក់ព័ន្ធនៃឯកសារនានាដែលខ្លួនស្នើសុំឲ្យទទួលយកធ្វើជាភស្តុតាងក្នុងសំណុំរឿង ០០២ និង

ខ. ច្រានចោលឯកសារទាំងឡាយណា ដែលមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យអប្បបរមាទាំងនេះ។

---

[57] *សូមមើល* ចម្លើយតបរបស់មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឲ្យមានសវនាការផ្ទាល់មាត់ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១១ ឯកសារលេខ E96/3 កថាខណ្ឌ៤-២១ សម្រាប់ការពន្យល់អំពីសិទ្ធិដាច់ខាតរបស់លោក អៀង សារី ក្នុងការតទល់ជាមួយនឹងសាក្សី ដែលឆ្លើយប្រឆាំងនឹងរូបគាត់ នៅក្នុងកិច្ចដំណើរការនីតិវិធីនោះចំពោះមុខ អ.វ.ត.ក។

[58] អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញផងដែរថា "មិនមាននូវមូលដ្ឋានផ្លូវច្បាប់ឡើយ នៅក្នុងច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ឬនៅក្នុងវិធានផ្ទៃក្នុង សម្រាប់ឲ្យអង្គជំនុំជម្រះធ្វើការកត់សម្គាល់នូវអង្គហេតុ ដែលបានវិនិច្ឆ័យរួចហើយ ឬអង្គហេតុនៃការដឹងឮជាទូទៅយកមកអនុវត្តនៅចំពោះមុខអ.វ.ត.កនោះទេ"។ សេចក្តីសម្រេចលើសំណើរបស់អៀង សារី ទាក់ទិននឹងការយកអង្គហេតុពីសំណុំរឿងលេខ០០១ ដែលបានវិនិច្ឆ័យរួចហើយ និងអង្គហេតុនៃការដឹងឮជាទូទៅមកអនុវត្តក្នុងសំណុំរឿងលេខ០០២ ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ E69/1 កថាខណ្ឌ ៣។

សូមលោក-លោកស្រីចៅក្រមអង្គជំនុំជម្រះសាលាដំបូង ទទួលយកសំណើនេះដោយក្តីគោរព។

__________________  __________________

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១១